

# របាយការណ៍ប្រចាំឆ្នាំ ២០២០

**BSDA**

អង្គការ សកម្មភាពព្រះពុទ្ធសាសនាដើម្បីអភិវឌ្ឍន៍សង្គម

**Buddhism for Social Development Action**

# អង្គការ សកម្មភាពព្រះពុទ្ធសាសនាដើម្បីអភិវឌ្ឍន៍សង្គម

# BUDDHISM FOR SOCIAL DEVELOPMENT ACTION

## របាយការណ៍សកម្មភាពប្រចាំឆ្នាំ ២០២០

## ចាប់ផ្តើម ខែមករា ដល់ខែធ្នូ ឆ្នាំ២០២០

## ផ្ញើដោយ


ទំនាក់ទំនង ៖ **លោក ថន វណ្ណុង**

នាយកប្រតិបត្តិអង្គការ

អាស័យដ្ឋាន៖ ផ្លូវជាតិលេខ៧ ភូមិអំពិលលើ ឃុំអំពិល ស្រុកកំពង់សៀម ខេត្តកំពង់ចាម ប្រទេសកម្ពុជា

ទូរសព្ទ័លេខ៖ (+៨៥៥) ៤២ ៥០ ៧៧ ៩៩៩/០១២ ៧៨៨ ៩៧៣

គេហទំព័រ៖ www.bsda-cambodia.org

សារអេឡិចត្រូនិច៖ director@bsda-cambodia.org

# មាតិការ៖


**I. សេចក្តីផ្តើម៖ ....................................................................................................5**

ក. ប្រវត្តិអង្គការ៖ ....................................................................................................5

ខ. អត្តសញ្ញាណអង្គការ៖ ....................................................................................................5

គ. គុណតម្លៃអង្គការ៖ ....................................................................................................5

ឃ .ទស្សនៈវិស័យអង្គារ៖....................................................................................................5

ង .បេសកកម្មអង្គការ៖....................................................................................................6

ច .គោលដៅអង្គការ៖ ....................................................................................................6

**II. កម្មវិធីរបស់អង្គការ៖....................................................................................................7**

**១. កម្មវីធីអប់រំ (EDUCATION PROGRAM)៖....................................................................................7**

**១.១. គម្រោង កុមារមេគង្គកម្ពុជា (MEKONG KAMPUCHEAD KIDS PROJECT)៖ ...................7**

១- ផ្តល់អាហារូបករណ៍៖....................................................................................................7

២- ភាសាអង់គ្លេស (ថ្នាក់ភាសាអង់គ្លេស)៖ ....................................................................................................8

៣- បណ្តុះបណ្តាលបំនិនជីវិត ផ្នែករបាំប្រពៃណីខ្មែរ និងផ្នែកភ្លេង៖ ....................................................................................................9

៤- មណ្ឌលសប្បាយសប្បាយ៖ ....................................................................................................9

៥- វិទ្យាស្ថាននៃក្តីញញឹម៖ ....................................................................................................10

៦- សាលាថ្នាក់បម្រុងបន្ថែម៖....................................................................................................11

៧-កម្មវិធីថៃទាំសុខភាពបឋម៖....................................................................................................12

៨-កម្មវីធី ថៃទាំបន្ត៖....................................................................................................12

**១.២. គម្រោង លើកកម្ពស់ការអប់រំ និងការងារនៅកម្ពុជា (STRENGTHENING EDUCATION AND EMPLOYABILITY IN KAMPUCHEAN PROJECT (SEEK)៖ .......................................... 13**

១- ចំនួនអ្នកទទួលផលសរុប៖ ....................................................................................................14

២- សមិទ្ធិផល ដែលសម្រេចបាន តាមសកម្មភាពនីមួយៗ៖ ....................................................................................................14

៣- បញ្ហាប្រឈម និងដំណោះស្រាយ៖....................................................................................................28

៤- សំណូមពរ៖.................................................................................................... 28

៥- ផែនការសម្រាប់ឆ្នាំបន្ទាប់៖ ....................................................................................................28

**១.៣. គម្រោង អប់រំអនាគតកុមារ (CHILD'S FUTURE EDUCATION PROJECT)៖................. 28**

១- ចំនួនអ្នកទទួលផលសរុបពីគម្រោង៖....................................................................................................29

២- សម្ទិផលដែលសម្រេចបានពីការអនុវត្តគម្រោង៖....................................................................................................29

៣- បញ្ហាប្រឈមនៅក្នុងការអនុវត្តគម្រោង៖....................................................................................................29

៤- ដំណោះស្រាយ៖ ....................................................................................................29

៥- សំណូមពរ៖ ....................................................................................................29

**១.៤. គម្រោង ការអប់រំជាមូលដ្ឋាន (BASIC EDUCATION PROJECT)៖ ..................................29**

១- សកម្មភាពរបស់គម្រោង ដែលបានអនុវត្តនៅក្នុងឆ្នាំ២០២០៖ .......... 30
២- លទ្ធផលសម្រេចបាន៖ .......... 30
៣- សំណូមពរ និងផែនការបន្ទាប់៖ .......... 30
**២. កម្មវិធីសុខភាព (HEALTH PROGRAM)៖ .......... 30**
**២.១. គម្រោងអាជីវកម្មខ្នាតតូច (FINANCING FUTURE PROJECT)៖ .......... 30**
១- គោលបំណងរបស់គម្រោង៖ .......... 30
២- សកម្មភាពអនុវត្តរបស់គម្រោងនៅក្នុងឆ្នាំ២០២០៖ .......... 30
៣- ការចុះត្រួតពិនិត្យ និងការបង្ហាត់បង្រៀនបន្ថែម៖ .......... 30
៤- ការបង្កើតប្រាក់ចំណូលតាមរយៈការលក់ និងបង្វិលប្រាក់ទុន៖ .......... 31
៥- ការប្រជុំប្រចាំខែជាមួយ អ្នកសន្សំប្រាក់៖ .......... 31
**២.២. គម្រោង ការធ្វើអោយប្រសើរឡើងនូវជីវភាពរស់នៅរបស់អ្នករស់នៅជាមួយមេរោគអេដស៍តាមរយៈការចិញ្ចឹមមាន់ (CHICKEN RAISING PROJECT)៖ .......... 31**
១- គោលបំណងរបស់គម្រោង៖ .......... 35
២- សកម្មភាពអនុវត្តរបស់គម្រោងនៅក្នុងឆ្នាំ២០២០៖ .......... 35
**៣. កម្មវិធីអភិបាលកិច្ចល្អ (GOOD GOVERNANCE PROGRAM)៖ .......... 35**
**៣.១. គម្រោង គណនេយ្យភាពសង្គម ធ្វើឲ្យប្រសើរឡើងនូវសេវាសាធារណៈ (IMPLEMENTATION OF SOCIAL ACCOUNTABILITY FOR BETTER PUBLIC SERVICE DELIVERY PROJECT (I-SAF_PHASE I)៖ .......... 35**
១- គោលបំណងរបស់គម្រោង៖ .......... 38
២- សកម្មភាពអនុវត្តគម្រោង៖ .......... 38
៣- បញ្ហាប្រឈម និងដំណោះស្រាយ៖ .......... 43
**៣.២. គម្រោង គណនេយ្យភាពសង្គម ធ្វើឲ្យប្រសើរឡើងនូវសេវាសាធារណៈ (IMPLEMENTATION OF SOCIAL ACCOUNTABILITY FOR BETTER PUBLIC SERVICE DELIVERY PROJECT (I-SAF_PHASE II)៖ .......... 41**
១- គោលបំណងរបស់គម្រោង៖ .......... 43
២- អ្នកទទួលផលសរុប៖ .......... 43
៣- សកម្មភាពអនុវត្តគម្រោង៖ .......... 43
៤- បញ្ហាប្រឈមរបស់គម្រោង៖ .......... 43
៥- សំណូមពររបស់គម្រោង៖ .......... 43
**III. សន្និដ្ឋាន៖ .......... 43**

# របាយការណ៍ស្តីពីលទ្ធផលការងារ
# សម្រាប់ការអនុវត្តនៅក្នុងឆ្នាំ ២០២០

## ១. សេចក្តីផ្តើម៖

### ក. ប្រវត្តិអង្គការ៖

អង្គការ សកម្មភាពព្រះពុទ្ធសាសនាដើម្បីអភិវឌ្ឍន៍សង្គម (Buddhism for Social Development Action (BSDA) គឺជាអង្គការ មិនមែនរដ្ឋាភិបាលក្នុងស្រុកមួយ ដែលបានបង្កើតឡើងនៅថ្ងៃទី០៥ ខែមករា ឆ្នាំ២០០៥ ដោយស្ថាបនិកជាព្រះសង្ឃចំនួន៧អង្គ គង់នៅវត្តនគរបាជ័យក្នុង និងទទួលស្គាល់ដោយក្រសួងមហាផ្ទៃ តាមប្រកាសលេខ ១៦២ ស.ជ.ណ ចុះថ្ងៃទី០៥ ខែកក្កដា ឆ្នាំ២០០៥ ។ អង្គការ BSDA មិនធ្វើការបម្រើឱ្យគណៈបក្សនយោបាយណា ឬក៏ផ្សព្វផ្សាយពីសាសនារបស់សមាជិកខ្លួនឡើយ។ អង្គការ BSDA គឺផ្តោតទៅលើតែ ការអភិវឌ្ឍន៍សង្គម និងជួយប្រជាជនក្រីក្រ ដែលកំពុងរស់នៅក្នុងសហគមន៍ក្រីក្រ។

### ខ. អត្តសញ្ញាណអង្គការ៖

អង្គការ BSDA គឺជាអង្គការធ្វើការជាមួយសហគមន៍ ដែលត្រូវបានបង្កើព្រះពុទ្ធសាសនានៃមេត្តាធម៌ដើម្បី ផ្តល់អំណោយដល់ប្រជាពលរដ្ឋ ដែលងាយរងគ្រោះនិងដើម្បី លើកកំពស់ការចូលរួមទំនាក់ទំនងល្អដោយ ក្តីអាណិតស្រឡាញ់នៅក្នុង សង្គម ហើយជួយធ្វើអោយការអភិវឌ្ឍន៍ សេដ្ឋកិច្ចកាន់តែខ្លាំង ដើម្បីរួមចំណែកលុបបំបាត់ភាពក្រីក្រនិងសេចក្តីទុក្ខដែលអាចជៀសផុតបាន។

### គ. គុណតម្លៃអង្គការ៖

ដោយផ្អែកទៅលើពាក្យប្រៀនប្រដៅពីការអនុវត្តធម៌មេត្តារបស់ព្រះពុទ្ធអង្គ[1] BSDAបានគោរពតាមនូវគុណតម្លៃដូចខាងក្រោម៖

- **បំរើជនក្រីក្រៈ** ធ្វើអោយបានប្រសើរឡើងនូវជីវភាពរស់នៅរបស់គ្រួសារដែលក្រីក្រ ។
- **រួបរួមសាមគ្គីៈ** កសាងនូវការជឿជាក់គ្នា ភាពស្មោះត្រង់ និងការគោរពគ្នាទៅវិញទៅមកជាគ្រួសារតែមួយ ។
- **យុទ្ធសាស្ត្របែបប្រជាធិបតេយ្យៈ** លើកតម្កើងអោយមានសម្លេងរួមគ្នា មកពីសមាជិកសហគមន៍ដៃគូធ្វើការជាមួយ បុគ្គលិកគ្រប់លំដាប់ថ្នាក់ និងការភ្ជាប់ពួកគេទៅនឹងដំណើរការ នៃការធ្វើសេចក្តីសម្រេចចិត្ត ។
- **ការសហការគ្នាៈ** ធ្វើការទាំងអស់គ្នា និងជាដៃគូជាមួយអ្នកផ្សេងៗដែលមកពីទីណាក៏ដោយអោយតែអាច ដើម្បីពង្រីកផលជះរបស់ពួកយើង ។
- **សុចរិតភាព និងគណនេយ្យភាពៈ** នៅក្នុងការគ្រប់គ្រងនិងការប្រើប្រាស់ជំនួយ ត្រូវប្រកបដោយគណនេយ្យភាពនិងតម្លាភាពដល់សហគមន៍ ម្ចាស់ជំនួយនិងអ្នកធ្វើការជាមួយគ្នា ។

### ឃ. ទស្សនៈវិស័យអង្គារ៖

អង្គការ BSDA ប្រាថ្នាចង់ឃើញសង្គមមួយ ដែលប្រជាពលរដ្ឋរស់នៅដោយឯករាជ្យ និងអាចចិញ្ចឹមជីវិតដោយខ្លួនបាន។

---

1 *មេត្តា = ការសាបព្រួសនូវការស្រលាញ់ដែលមិនអាត្មានិយម ហើយនិងក្តីមេត្តា ជាជាងសាបព្រួសនូវភាពជាមិត្តដែលផ្អែកលើផលប្រយោជន៍ផ្ទាល់ខ្លួន។*

### ង. បេសកកម្មអង្គការ៖

បេសកកម្មរបស់អង្គការ BSDA គឺលើកកំពស់ជីវភាពរស់នៅរបស់ប្រជពលរដ្ឋ ដែលងាយរងគ្រោះ ជាពីសេស ស្រ្តី កុមារ និងយុវជន តាមរយៈ វិស័យអប់រំ សុខភាព និងការផ្ដួចផ្ដើមអភិវឌ្ឍន៍ ជីវភាពការរស់នៅជាដៃគូរជាមួយអ្នកផ្សេងទៀត ។

### ច. គោលដៅអង្គការ៖

- ដើម្បីជួយដល់កុមារនិងយុវជនដែលងាយរងគ្រោះ អោយមានភាពប្រសើរក្នុងការទទួល បានការ អប់រំ និងលើសពីនេះទៅទៀតយុវជនត្រូវបានផ្ដល់នូវជំនាញបច្ចេកទេសតាមរយៈ ការបណ្ដុះ បណ្ដាលវិជ្ជាជីវៈដែលធានាអោយមានជីវភាពប្រកបដោយនិរន្តរភាព ។

- ដើម្បីធ្វើឱ្យប្រសើរឡើងនូវសុខុមាលភាពសហគមន៍ តាមរយៈការអាចកាន់តែទទួលបានសេវា ថៃទាំសុខភាពតាមសហគមន៍ ដែលប្រកបដោយគុណភាព និងធ្វើអោយយល់ដឹងពីផ្នែកសំខាន់ៗ នៃសុខភាពសាធារណៈកាន់តែល្អប្រសើរឡើង ។

- ដើម្បីអោយប្រសើរឡើង ត្រៀមសម្រាប់ការផ្លាស់ប្ដូរអាកាសធាតុ ដោយការបង្កើនការយកចិត្ត ទុកដាក់បន្ថែមទៀតក្នុងការការពារបរិស្ថាន និងការប្រែប្រួលអាកាសធាតុ ។

- ដើម្បីធ្វើអោយមានអភិបាលកិច្ចកាន់តែល្អ ជាការថែមទៅលើផែនការដែលមានស្រាប់ និងការផ្ដល់ សេវាសាធារណៈក្នុងការបំពេញនូវតម្រូវការសហគមន៍អោយបានរឹងរិតតែល្អ ។

- ដើម្បីធ្វើអោយប្រជាពលរដ្ឋនៅជនបទ ដែលមិនទួលបានផលប្រយោជន៍អ្វី អោយមានឱកាសអាចបង្កើតចំណូលបាន និងគាំទ្រអោយមាននិរន្តរភាព និងបង្កើតសកម្មភាព ដែលមិនរកប្រាក់កម្រៃ ចំណេញរបស់អង្គការ ដើម្បីពង្រីកផលអោយបានកាន់តែប្រសើរថែមទៀត ។

## ២. កម្មវិធីរបស់អង្គការ៖

## ១. កម្មវិធីអប់រំ (EDUCATION PROGRAM)៖

### ១.១. គម្រោង កុមារមេគង្គកម្ពុជា (MEKONG KAMPUCHEAD KIDS PROJECT)៖

**ក. គោលបំណង** ៖ ជួយគាំទ្រដល់ក្មេងកំព្រា ងាយរងគ្រោះ បាត់បង់ឱកាស និងក្មេងៗ ដែលរស់នៅ នៅតាមចិញ្ចើមថ្នល់ ដើម្បីផ្តល់គុណភាព នៃការរស់នៅរបស់ពួកគេ អោយបានល្អប្រសើរឡើង ។

**ខ. ចំនួនបុគ្គលិកសរុប** ៖ ២៣នាក់ (ស្រី១៤ នាក់)
**គ. ទីតាំងគម្រោង** ៖ ខេត្តកំពង់ចាម នៅក្នុងវត្តនគរបាជ័យក្នុង និងវិទ្យាស្ថាន នៃក្តីញញឹម
**ឃ. សរុបថវិកាគម្រោង** ៖ ១៧,០៥៤.៥៤ ដុល្លា
**ង. កាលបរិច្ឆេទគម្រោង** ៖ ១ឆ្នាំ (ថ្ងៃទី០១ ខែមករា ដល់ ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២០)
**ឆ. សកម្មភាពអនុវត្តគម្រោង៖**

| ប្រភេទអ្នកទទួលផលពីគម្រោង | ចំនួនអ្នកទទួលផលផ្តល ចាប់ពី ខែមករា ដល់ ខែធ្នូ ឆ្នាំ២០២០ | |
|---|---|---|
| | សរុប | ស្រី |
| I-សិស្សអាហារូបករណ៍: | | |
| ១. អាហារូបករណ៍ សិស្សក្រីក្រនៅសហគមន៍ | ៧៧ | ៥១ |
| ២. អាហារូបករណ៍ ម្តាយធម៌ | ០ | ០ |
| ៣. អាហារូបករណ៍ កុំព្យូទ័រ | ០ | ០ |
| ៤. អាហារូបករណ៍ រៀនភាសាអង់គ្លេស (ជាសិស្សមកពីអាហារូបករណ៍ និងជាសិស្សក្រីក្រនៅសហគមន៍) | ៤៤៤ | ២៧០ |
| II-សិស្សបណ្តុះបណ្តាលវិជ្ជាជីវៈ | ៤០ | ១៥ |
| III. សិស្សថៃទាំបន្ត (សិស្សចប់ជំនាញ) | ៩៥ | ៤០ |
| IV-សិស្សបណ្តុះបណ្តាលបំនិនជីវិត ផ្នែករបាំប្រពៃណីខ្មែរ និងផ្នែកភ្លេង | | |
| ១. សិស្សនៅក្នុងមណ្ឌលអប្សរា | ៧៩ | ៥៦ |
| ២. សិស្សនៅក្នុងមណ្ឌលសប្បាយសប្បាយ | ៣៦ | ២២ |
| សរុប៖ | ៧៧១ | ៤៥4 |

**១- ផ្តល់អាហារូបករណ៍៖**



ក្នុងឆ្នាំ២០២០ គម្រោងកុមារមេគង្គកម្ពុជាបានផ្តល់អាហារូបករណ៍ដល់សិស្សក្រីក្រតាមសាលា ក្នុងស្រុកកំពង់សៀម និងក្រុងកំពង់ចាម សរុបសិស្ស៧៧នាក់ (ស្រី៥១) ក្នុងនោះសិស្សម្នាក់ទទួលបាន អង្ករ ២៥គីឡូ ប្រេងឆា១ដប ស្ករ១គីឡូ អំបិលអ៊ីយ៉ូត០.៥គីឡូ ទឹកត្រី១ដប ទឹកស៊ីអ៊ីវ១ដប និងត្រីខ២កំប៉ុង ស្មើរនឹងទឹកប្រាក់ចំនួន១៥ដុល្លារសហរដ្ឋអាមេរិចជារៀងរាល់ខែ។ ក្រៅពីនេះគម្រោងបានផ្តល់សម្ភារសិក្សាដល់សិស្ស

ទាំងអស់ក្នុងម្នាក់ៗទទួលបាន សៀវ ភៅ ប៊ិច ខ្មៅដៃ បន្ទាត់ ជ័រលប់ កាប៉ូក និងសំលៀកបំពាក់១កំផ្លេ។ អាហារូបករណ៍នេះផងដែរទទួលបានជំនួយពីអង្គការ អេកូសូលីដានៅប្រទេសស្វីសតាមរយៈអង្គការ សកម្មភាពព្រះពុទ្ធសាសនាដើម្បីអភិវឌ្ឍន៍សង្គម។

ក្នុងឆ្នាំ២០២០នេវគ្គរបស់គម្រោងកុមារមេគង្គកម្ពុជាបានជួយសម្រួលដល់សិស្សានុសិស្សដែលមានជីវភាពក្រលំបាកដែលមានផ្ទះនៅឆ្ងាយពីសាលា និងសិស្សដែលរៀនពូកែបានពន្ទុខ្ពស់ក្នុងថ្នាក់នូវកង់មួយគ្រឿងដើម្បីជាការលើកទឹកចិត្តដល់អាណាព្យាបាល ឬឪពុកម្តាយ ក៏ដូចសាម៉ីខ្លួនផងដែរ។

ដោយឡែកនៅចុងឆ្នាំ២០១៩ និង ឆ្នាំ២០២០នេះ ផ្នែកអាហារូបករណ៍ ក៏ដូចផ្នែកដទៃទៀតត្រូវបានផ្អាកចួបជុំជាក្រុមមនុស្សច្រើនដោយសារមានវិបត្តិជំងឺឆ្លងកូវីត-១៩ ប៉ុន្តែគម្រោងនៅតែបន្តចែកអាហារូបករណ៍ដល់សិស្សម្នាក់ៗតាមផែនការណ៍ដែលគ្រោងទុក ។

| បញ្ហាជួបប្រទះ | ដំណោះស្រាយ |
|---|---|
| ១. សិស្សទៅរៀនមិនទៀងទាត់នៅសាលារដ្ឋ<br>២. សិស្សមួយចំនួនមិនសូវមានអនាម័យ | រៀបចំកាលវិភាគថ្មី ដើម្បីចួបប្រជុំជាមួយអាណាព្យាបាលនិងឪពុក ម្តាយដើម្បីពន្យល់អំពីសារសំខាន់នៃការសិក្សា ក៏ដូចអនាម័យខ្លួនប្រាណ ។<br>ម្យ៉ាងទៀតព្យាយាមឲ្យសិស្សានុសិស្សអនុវត្តជារៀងរាល់ថ្ងៃ និងលើកទឹកចិត្តអាណាព្យាបាល ក៏ដូចជាឪពុកម្តាយដើម្បីជំរុញឲ្យកូនមករៀនឲ្យបានទៀងទាត់ទាំងនៅមណ្ឌល និងសាលារដ្ឋនិងបង្កើនការអប់រំផ្នែកសុខភាពអនាម័យទ្វេដង ។ |

### ២- ភាសាអង់គ្លេស (ថ្នាក់ភាសាអង់គ្លេស)៖

ថ្នាក់បង្រៀនភាសាអង់គ្លេសបន្ថែម មាន២កន្លែងនៅមណ្ឌលបណ្តុះបណ្តាលវិជ្ជាជីវៈ (វិទ្យាស្ថាននៃក្តីញញឹម) ចំនួន ៣៣នាក់ ស្រី១១នាក់ ត្រូវបានបង្រៀនដោយឥតគិតថ្លៃ និងការអប់រំសីលធម៌សង្គមដើម្បីបន្ទន់ឥរិបថសម្រាប់ប្អូនៗជំនាន់ថ្មី។ រីឯថ្នាក់ភាសាអង់គ្លេសនៅសាលាបឋមសិក្សា និងអនុវិទ្យាល័យអង្គរៀងរាល់ម៉ោង ៥ ដល់ ម៉ោង ៧ល្ងាច ទទួលបានសិស្សចំនួន ៤៤៤នាក់ ស្រី២៧០នាក់ ពួកគាត់ ទទួលបានចុះតម្លៃ ៥០% ធៀបទៅនឹងសាលាឯកជន ដែលគេយក ១០០% សម្រាប់សិស្សក្រីក្រ ។





ដោយសារមានជម្ងឺឆ្លងកូវីត-១៩ សាលាបង្រៀនភាសាអង់គ្លេសត្រូវបានឈប់ដំណើរការមួយរយៈ ដោយសារ ចូលរួមបង្ការ និងទប់ស្កាត់ក្នុងរីករាលដាលក្នុងសហគមន៍ ដូច្នោះគម្រោងនឹងបើកបង្រៀនសាលាភាសាអង់គ្លេសវិញនៅក្នុងខែមករា ឆ្នាំ២០២១ នេះបន្តទៀត ។

## ៣- បណ្តុះបណ្តាលបំនិនជីវិត ផ្នែករបាំប្រពៃណីខ្មែរ និងផ្នែកភ្លេង៖





នៅមណ្ឌលអប្សរា បានបណ្តុះបណ្តាលដល់ក្មេងៗ ដែលនៅជុំវិញវត្តនគរបាជ័យ និងក្មេងនៅក្នុងសហគមន៍មានចំនួនសរុប៧៩នាក់ សិស្សស្រីមានចំនួន ៥៦នាក់។ គម្រោងបានដឹកជញ្ជូនពួកគាត់ពីសហគមន៍មកកាន់មណ្ឌល និងពីមណ្ឌលទៅកាន់សហគមន៍វិញដោយប្រើយានជំនិះកង់បីជារៀងរាល់ថ្ងៃដើម្បីកុំអោយពួកគាត់ពិបាកក្នុងការធ្វើដំណើរ។ នៅពេលកំពុងរៀននៅទីនេះអង្គការបានផ្តល់អាហារសម្រន់ជារៀងរាល់ថ្ងៃដល់សិស្សានុសិស្ស។ ជាលទ្ធផលពួកគាត់អាចសំដែងជូនភ្ញៀវក្នុងពិធីផ្សេងៗបាន ដូចជារបាំជូនពរ នារីជាជួរ អប្សរា គោះត្រឡោក ក្រមា ក្មោកប៉ៃលីន បុកលក្ខ នៃយ៉ាំ... និងរបាំត្រុដិជាដើម។ សម្រាប់សិស្សតូចៗ ត្រូវបានផ្តល់ការបណ្តុះបណ្តាលបន្តពីលោកគ្រូរបាំផ្ទាល់ និងសិស្សច្បងជាបន្តបន្ទាប់។ ឆ្នាំនេះផងដែរ ក្រុមសិល្បៈ ដែលដឹកនាំដោយលោកគ្រូរបាំបានចេញសំដែងរបាំបានចំនួន៦ដងតាមកម្មវិធីផ្សេងៗក្នុងខេត្តកំពង់ចាម និងខេត្តផ្សេងទៀតបានយ៉ាងល្អ ប្រកបដោយទំនុកចិត្តខ្ពស់ពីអតិថិជន។

ចំណែកភ្លេងប្រពៃណីមានសិស្សសរុបចំនួន២៤នាក់ សិស្សស្រីមានចំនួន ២០នាក់ ដែលចេញមកពីសិស្សរបាំពួកគាត់ទទួលបានការបង្ហាត់ភ្លេងពិណពាទ្យ និងភ្លេងប្រពៃណីខ្មែរ(ភ្លេងការ) បង្ហាត់ដោយលោកគ្រូ ហុន ម៉េងហុងដែលជំនាញភ្លេងប្រពៃណី និងអាយ៉ៃ និងជាអតីតសិស្សពិការភ្នែកមកពីអង្គការគ្រួសារថ្មី។ រាល់បទភ្លេងដែលបានបង្រៀនគឺសាច់ភ្លេងទូទៅ និងសាច់ភ្លេងសម្រាប់បង្គុំរាំរបាំប្រពៃណី និងអប្សរា។

ជាលទ្ធផលក្នុងឆ្នាំ២០២០ លោកគ្រូភ្លេងបានដឹកនាំកូនក្រុមចេញសំដែងបានចំនួន៣ដងក្នុងកម្មវិធីផ្សេងៗ ទាំងនៅក្នុងខេត្ត និងនៅក្រៅខេត្តផងដែរ។

ដោយសារមានការឆ្លងរីករាលដាលជម្ងឺកូវីត-១៩ ជាសកល ហេតុដូច្នេះហើយបានជាភ្លេង និងរបាំមិនបានចេញទៅសម្តែងតាមកម្មវិធីផ្សេងៗ ដូចឆ្នាំកន្លងទៅ។

| បញ្ហាជួបប្រទះ | ដំណោះស្រាយ |
|---|---|
| សិស្សរៀនភ្លេងជាប់រៀនសាលារដ្ឋពីរវេលាព្រឹក និងល្ងាច ។ | អនុញ្ញាតឲ្យសិស្សដែលរៀនពីរវេលាព្រឹក ល្ងាចមកហាត់សមនៃថ្ងៃអាទិត្យ ឬថ្ងៃដែលទំណេរពីការសិក្សា។ |
| ខ្វះអ្នកលេងភ្លេងពេលមានកម្មវិធីសម្តែងម្តងៗ | អញ្ជើញអ្នកខាងក្រៅមកលេងជំនួស និងពង្រឹកសិស្សបន្ថែមនៃថ្ងៃអាទិត្យ។ |
| ជម្ងឺកូវីត-១៩ ។ | កាត់បន្ថយចំនួនសិស្សក្នុងការបង្រៀន និងមានគម្លាតសង្គម។ |

## ៤- មណ្ឌលសប្បាយសប្បាយ៖



នៅមណ្ឌលសប្បាយសប្បាយ គម្រោង កុមារមេត្តកម្ពុជា បានកំពុងអនុវត្ត គម្រោងអប់រំក្រៅប្រពន្ធ័ គឺបង្រៀនចំណេះដឹងទូទៅ សុខភាព អនាម័យ និង ភាសាអង់គ្លេសត្រៀមមុនចូលរៀន និងកំពុងសិក្សា។ សរុបឆ្នាំ២០២០ នេះសិស្សដែលបានទទួលសេវាពីមណ្ឌលសប្បាយសប្បាយមានចំនួនសិស្សសរុប៣៦នាក់ សិស្សស្រីមានចំនួន២២នាក់។ លើសពីនេះទៀត បុគ្គលិកគម្រោងបានចុះផ្សព្វ ផ្សាយ ចំណេះដឹងដល់សហ

គមន៍ ស្តីអំពីការប្រើអំពើហឹង្សារក្នុងគ្រួសារ សិទ្ធិកុមារ សារៈសំខាន់នៃការសិក្សា ពលកម្មកុមារ និងការធ្វើចំណាកស្រុកដោយសុវត្ថិភាពដល់អាណាព្យាបាលរបស់សិស្សទាំងអស់ ចំនួន៩ដង ដែលមានអ្នកចូលរូមសរុប៦៩៣នាក់ ស្រីមានចំនួន៥១៩នាក់ នៅតាមសហគមន៍គោលដៅ។ ជាលទ្ធផលធ្វើអោយកូនៗ របស់ពួកគាត់មានចំណេះដឹងកើនឡើង អត្រាបោះបង់សាលាមានការថយចុះ។ យោងតាមការធ្វើតេស្តប្រឡងបង្ហាញអោយឃើញថា ៧៩% នៃសិស្សនៅមណ្ឌលសប្បាយសប្បាយ មានពិន្ទុកំរិតល្អ ៨%ល្អបង្គួរ ៣១%មធ្យម ហើយ ៦១%ដែលពិន្ទុទាប។

ចំពោះអាគារ និងបរិវេណមណ្ឌលសប្បាយសប្បាយ ត្រូវបានអនុញ្ញាតិពីមន្ទីរសង្គមកិច្ច ខេត្តកំពង់ចាមអោយប្រើប្រាស់ និងអោយមានការកែឆ្នៃ ឬសង់បន្ថែម និងកែលំអរផ្សេងៗដើម្បីជាប្រយោជន៍ដល់កុមារក្រីក្រនៅសហគមន៍នៃក្រុងកំពង់ចាម ។ ក្នុងឆ្នាំកន្លងមករហូតដល់ឆ្នាំ២០២០មណ្ឌលសប្បាយសប្បាយមិនបានសាងសង់អ្វីជាដុំកំភួនទេ ដោយសារវិបត្តិជំងឺកូវីត ១៩ដែលធ្វើឲ្យសកម្មភាពមួយចំនួនត្ុវបានផ្អាកជាបណ្តោះអាសន្ន។

| បញ្ហាជួបប្រទះ | ដំណោះស្រាយ |
|---|---|
| សិស្សមិនបានមករៀនដោយសារជំងឺកូវីត ១៩ និងអាគារត្រូវបានលិចនៅរដូវវស្សា។ | គ្រូគម្រោងចុះបង្រៀនតាមផ្ទះ និងផ្តល់សម្ភារបង្រៀនដល់អាណាព្យាបាល ឬឪពុកម្តាយដើម្បីបង្រៀនកូនតាមផ្ទះដោយមានការជួយពីកម្មវិធីសិក្សារបស់ក្រសួងតាមរយៈប្រព័ន្ធផ្សព្វផ្សាយសង្គម ។ |

### ៥- វិទ្យាស្ថាននៃក្តីញញឹមៈ

នៅក្នុងឆ្នាំ ២០២០ នៅចុងឆមាសទីII នៃសិស្សជំនាន់ទីIX បានបញ្ចប់វគ្គចំនួន ១០នាក់ សិស្សស្រីមានចំនួន៦នាក់ ហើយអង្គការ បានធ្វើសមាហរណកម្មពួកគាត់ទៅសហគមន៍វិញ។ ចំណែកជំនាន់ទីX បានចាប់ផ្តើមបន្តវគ្គថ្មីក្នុងឆមាសទីI សិស្សមានចំនួន១៩នាក់ បូករួមទាំងសិស្សសាលារដ្ឋមានចំនួន៧នាក់ សិស្សស្រីមានចំនួន១១នាក់។

### ក- ការងារសាងសង់ៈ





ដោយមានការសហការណ៍ល្អរវាងមន្ត្រីសង្គមកិច្ចផ្នែកសុខមាលភាពកុមារខេត្តកំពង់ចាម និង អង្គការ សកម្មភាពព្រះពុទ្ធសាសនាដើម្បីអភិវឌ្ឍន៍សង្គម គម្រោងបានធ្វើការជួសជុល និងកែលំអរអាគារមួយចំនួនដូចជា អាគារស្នាក់នៅសម្រាប់ក្មេងស្រី និងក្មេងប្រុស អាហារដ្ឋាន របងខ័ណ្ឌចែកជាពីររវាងមណ្ឌល និងការិយាល័យកណ្តាល ដាក់វាំងននតាមបង្អួច ដាក់គ្រែគេង ប្រព័ន្ធចំរុះទឹកស្អាត បន្ទប់ប្រឹក្សាយោបល់ បំពាក់បំពងពន្លត់អគីសភ័យថ្មី ប្រព័ន្ធទឹកភ្លើង ទូរដាក់ខោអាវរបស់សិស្សានុសិស្ស កីឡាស្ថាន ដាក់ឈ្មោះតាមអាគារ បន្ទប់និមួយៗ និងហេដ្ឋារចនាសម្ពន្ធ័ផ្សេងៗទៀនៅក្នុងបរិវេណ។ មណ្ឌលបានបញ្ចប់រួចរាល់ហើយនោះ អង្គការនៅតែមាន គម្រោងសាងសង់ និងជួលជុលបន្តរហូតទៅតាមលទ្ធភាព។ ដោយឡែកនៅឆ្នាំ ២០២០នេះផងដែរ គម្រោងបានរៀបចំឲ្យមានសួនបន្លែតាមគ្រួសារនិមួយៗដើម្បីជាជំនួយទាំងស្មារតី និងកាយសម្បទាដើម្បីជាប្រយោជន៍ដល់សិស្សានុសិស្សដែលរស់នៅក្នុងមណ្ឌល ៕

### ខ- ផលិតផលសន្តិសុខស្បៀង និងការផ្តល់ជំនាញការចិញ្ចឹមជីវិតដល់សិស្សានុសិស្ស៖





**ការដាំបន្លែ៖** បន្លែគឺជាអាហារមួយដ៏សំខាន់សម្រាប់ទ្រទ្រង់ការរស់នៅក្នុងមណ្ឌល ដូច្នោះគម្រោងក៏បានពង្រីកទីធ្លាបន្ថែមដោយប្រើប្រើកង់ឡានចាស់ៗធ្វើជាថ្នើដើម្បីឲ្យបន្លែលូតលាស់បានល្អ ម្យ៉ាងទៀតយើងធ្វើបែបនេះដើម្បីកាត់បន្ថយការទិញបន្លែពីផ្សារដែលមានតម្លៃខ្ពស់ សម្រាប់ឆ្នាំ ២០២០ ជាសរុបបន្លែដែលដាំបានគិតជាចំនួនសាច់ប្រាក់មានចំនួន៥០៥ ដុល្លាសហរដ្ឋអាមេរិក។ រហូតមកដល់ចុងឆ្នាំ យើងបានដាំស្វាយបន្ថែម ដាំចេក ដាំខ្នុរ ដាំទៀបបារាំង ព្រីង ទលឹងទីង ទៀបខ្មែរ មៀន និងរុក្ខជាតិហូបផ្លែមួយចំនួនទៀតនៅជុំវិញមណ្ឌលដើម្បីផ្គត់ផ្គង់អាហារហូបចុកប្រចាំថ្ងៃរបស់សិស្សានុសិស្សដែលកំពុងសិក្សាជំនាញ។ ម្យ៉ាងទៀតនោះវាជាផ្នែកមួយនៃបំពេញបន្ថែម និងការទ្រទ្រង់ការចិញ្ចឹមជីវិតប្រចាំថ្ងៃ របស់សិស្សមណ្ឌល និងការកាត់បន្ថយចំណាយការទិញម្ហូបប្រចាំថ្ងៃផងដែរ។ សរុបប្រចាំថ្ងៃ។ បន្លែមពីនេះទៀត ដាំមាន ត្រកួន ឆៃថូវ ស្ពៃបូកគោ ហើយវារស់តាមបែបធម្មជាតិ មិនប្រើគីមី ដោយវាលូតលាស់តាមជីធម្មជាតិដែលនៅជុំវិញមណ្ឌលដំណាំនេះពួគប្រើប្រាស់ជារៀងរាល់ថ្ងៃពេលដែល សម្រាប់បំពេញតម្រូវការក្នុងខណៈពេល ម្ហូបទិញពីផ្សារមិនគ្រប់គ្រាន់។

| បញ្ហាជួបប្រទះ | ដំណោះស្រាយ |
|---|---|
| ខ្វះបច្ចេកទេសក្នុងការដាំដុះ និងថែទាំ។<br>តម្រូវការបន្លែខ្ពស់ជារៀងរាល់ថ្ងៃ។ | ព្យាយាមសួរអ្នកជំនាញ<br>បង្រីកដីដាំដុះបន្លែម |
| ចំពោះបន្លែនៅតែមានសត្វល្អិតមកស៊ីបំផ្លាញបន្លែធម្មជាតិ ដីដែលកំពុងដាំបន្លែភាគច្រើនសម្បូរទៅដោយ ជាតិអាស៊ីត ធ្វើអោយបន្លែលូតលាស់យឺត។ | បុគ្គលិកគម្រោងនឹងបង្កើតជាតិពុលធម្មជាតិដើម្បីបណ្តេញសត្វទាំងនោះចេញ<br>បុគ្គលិកជំនាញនឹងប្រើប្រាស់កំបោរកសិកម្មដើម្បីកាត់បន្ថយជាតិអាស៊ីត។ |

### ៦- សាលាថ្នាក់បម្រុងបន្ថែម៖



ថ្នាក់ត្រៀមបានផ្តល់ជូនដល់សិស្សជំនាញជំនាន់ទីIX មុនពេលពួកគេបញ្ចប់ជំនាញនៅ ចុងឆមាសទីII ជាលក្ខណសិក្ខាសាលា និងបណ្តុះបណ្តាលដូចជា ផែនការអនាគតមុនចេញទៅរកមុខរបរ ផែនការទីផ្សារ របៀបចាប់ផ្តើមអាជីវកម្មខ្នាតតូច និងរបៀបសរសេរបែបបទដើម្បីរកការងារធ្វើ បំនិនជីវិត សុខភាពបន្តពូជ ជំងឺអេដស៍ សិទ្ធិមនុស្ស គណិតវិទ្យា ភាសាខ្មែរ មូលដ្ឋានគ្រឹះភាសាអង់គ្លេស ជំងឺឆ្លងកូវីត ១៩ ល និងល ។ នេះដើម្បីប្រាកដថា ពេលពួកគាត់ចេញពីមណ្ឌលបណ្តុះបណ្តាលទៅ ពួកគាត់ធ្វើការអ្វី នៅកន្លែងណា បានចំនូលប៉ុន្មាន។ ចំណែកជំនាន់ទីXទើបតែជ្រើសរើសបានថ្មីអោយចូលរៀននៅក្នុងត្រីមាសទីI ក្នុងខែមករា ឆ្នាំ២០២១ ត្រូវបានផ្តល់ការសិក្សាចំណេះដឹងទូទៅចំនួន១៣មុខវិជ្ជា ដូចជា គណិតវិទ្យា ខ្មែរវិទ្យា ភាសាអង់គ្លេស ភូមិ ប្រវត្តិ សិលធម៌ អាជីវកម្មខ្នាតតូច ល និងល មុនពួកគាត់ចាប់យកជំនាញ ហើយក្រៅពីនេះគម្រោងផ្តល់វគ្គសិក្ខាសាលាផ្សេងៗដូចមុនៗដែរ។ បន្ទាប់ពីពួកគាត់បានចប់ថ្នាក់ត្រៀម បុគ្គលិក

គម្រោងបានធ្វើបទបង្ហាញមួយស្ដីអំពីការណែនាំតម្រង់ទិសដល់ពួកគាត់មុនពេលចាប់យកជជំនាញ។ ដោយឡែក ឆ្នាំ២០២០ នេះសិស្សជំនាញដែលមានចំនួន ២៨នាក់ សិស្សស្រីមានចំនួន៩នាក់ សិស្សផាត់មុខមានចំនួន៤នាក់ កាត់សក់បុរស១នាក់ ជួសជុលម៉ាស៊ីនត្រជាក់៥នាក់ ជួសជុលម៉ូតូ ៧នាក់ បដិសណ្ឋារកិច្ច ផ្នែកចុងភៅ១១នាក់ ស្រីមានចំនួន៦នាក់ សិស្សរៀនជំនាញឡានតូចមានចំនួន១នាក់ សិស្សទាំងអស់ត្រូវបានគម្រោងបញ្ជូនឲ្យទៅរៀននៅខាងក្រៅ លើកលែងតែជំនាញមេកានិចផ្នែកជួសជុលម៉ូតូ និងសណ្ឋាគារ និងបដិសណ្ឋារកិច្ចតែប៉ុន្នោះដែលគម្រោងមានគ្រូប្រចាំការក្នុងមណ្ឌល។

### ៧-កម្មវិធីថែទាំសុខភាពបឋម៖





សិស្សទាំង ៤០នាក់ ស្រីមានចំនួន១៥នាក់ មានការមើលថែទាំពីអ្នកគ្រូពេទ្យជាប្រចាំនៅក្នុងមណ្ឌល។ ក្នុងនោះផងដែរមានសិស្សចំនួន១១នាក់ ស្រី៥នាក់មានផ្ទុកមេរោគអេដស៍ទទួលបានការថែទាំដោយយកចិត្តទុកដាក់ និងប្រុងប្រយត្ន័។ សម្រាប់សិស្សដែលមានជម្ងឺធ្ងន់ធ្ងរ អង្គការនឹងបញ្ជូនទៅមន្ទីរពេទ្យខេត្តដើម្បីជួយព្យាបាលដោយឥតគិតថ្លៃ និងមានការសហការយ៉ាងល្អ។ ក្រៅពីនេះទៀត ពួកគាត់ត្រូវបានផ្ដល់ការព្យាបាលផ្សេងពីអ្នកគ្រូពេទ្យប្រចាំវិទ្យាស្ថានមានដូចជា ឈឺក្បាល ឈឺពោះ ផ្ដាស់សាយ និងជម្ងឺស្រាលៗមួនចំនួនទៀតនៅក្នុងមណ្ឌលផ្ទាល់។ ដោយឡែកនៅក្នុង២ឆ្នាំចុងក្រោយនេះ គម្រោងមានផលលំបាកមួយចំនួន ដែលបង្កដោយជម្ងឺកូវីត-១៩ ដែលតម្រូវឲ្យសិស្សានុសិស្សស្ថិតក្នុងមណ្ឌលមួយរយះ ដោយខ្លាចមានការឆ្លងរីករាលដាលធ្វើអោយពិបាកក្នុងការទប់ស្កាត់ និងបង្ការ ហេតុដូច្នោះហើយបានមណ្ឌលតាមរយៈបុគ្គលិកពេទ្យប្រចាំគម្រោងបានរៀបចំសិក្ខាសាលាមួយចំនួនដើម្បីឆ្លើយតបទៅនឹងស្ថានភាពបច្ចុប្បន្នពិសេសអប់រំសុខភាពទាក់ទងទៅនឹងជំងឺឆ្លង។

| បញ្ហាជួបប្រទះ | ដំណោះស្រាយ |
|---|---|
| ខ្វះជំនាញផ្ដល់ប្រឹក្សាយោបល់បញ្ហាអនាម័យ និងជំងឺកូវីត-១៩ | គម្រោងនឹងផ្ដល់ជំនាញនេះបន្ថែមដល់បុគ្គលិក ធ្វើការអប់រំបន្ថែមទៅដល់អ្នកមើលថៃ និងណែនាំសិស្សានុសិស្សឲ្យប្រកាន់ភ្ជាប់ក្បួន នៃក្បួនអនាម័យក្នុងការរស់នៅ ។ |

### ៨-កម្មវិធី ថែទាំបន្ត៖

គិតពីចាប់ផ្ដើមរហូតមកដល់ឆ្នាំ២០២០ សិស្សដែលបានរៀនចប់ជំនាញក្នុងមណ្ឌលបណ្ដុះបណ្ដាលវិជ្ជាជីវៈ មាន IX ជំនាន់ សរុបចំនួន៩៥នាក់ សិស្សស្រីមានចំនួន៤០នាក់ ជាក់ស្តែងសិស្ស ដែលធ្វើការត្រូវជំនាញផ្នែកសណ្ឋាគារ និងបដិសណ្ឋារកិច្ចមានចំនួន១៨នាក់ ស្មើនឹង១៨.៩៥% សិស្សដែលធ្វើការខុសជំនាញមានចំនួន៦នាក់ ស្មើនឹង ៦.៣២% ហើយសិស្សដែលមានអាជីវកម្មខ្លួនឯងមានចំនួន២នាក់ស្មើនឹង ២.១១% នៃសិស្សដែលរៀនជំនាញសណ្ឋាគារ និងបដិសណ្ឋា។ ផ្នែកផាត់មុខមានសិស្សចំនួន១២នាក់ សិស្សធ្វើការត្រូវជំនាញមានចំនួន៩នាក់ ស្មើនឹង ៩.៤៧% សិស្សបើកអាជីវកម្មខ្លួនឯងមានចំនួន៣នាក់ស្មើនឹង ៣.១៦% ផ្នែកកាត់សក់បុរសមានអាជីវកម្មខ្លួនឯងមានចំនួន២នាក់ស្មើនឹង២.១១% ។ ផ្នែកមេកានិច ជំនាញជួសជុលម៉ូតូមានចំនួន១៧នាក់បានបញ្ចប់ សិស្សធ្វើការត្រូវចំនាញមានចំនួន ១២នាក់ ស្មើនឹង១២.៦៣% សិស្សធ្វើការខុសជំនញមានចំនួន៤នាក់ស្មើនឹង ៤.២១%អត់

ការងារធ្វើចំនួន១នាក់ ស្មើនឹង១.០៥%។ ផ្នែកជួសជុលឡានមានចំនួន១នាក់បានបញ្ចប់ ហើយនិងធ្វើការខុសជំនាញស្មើនឹង ១.០៥%។ ផ្នែកអេឡិចត្រូនិច ជំនាញជួសជុលម៉ាស៊ីនត្រជាក់មានចំនួន៩នាក់បានបញ្ចប់ សិស្សធ្វើការត្រូវជំនាញមានចំនួន៥នាក់ ស្មើនឹង ៥.២៦% សិស្សធ្វើការខុសជំនាញមានចំនួន២នាក់ ស្មើនឹង ២.១១% សិស្សអត់ការងារធ្វើមានចំនួន១នាក់ ស្មើនឹង ១.០៥% និងសិស្សមានអាជីវកម្មខ្លួនឯងមានចំនួន១នាក់ ស្មើនឹង ១.០៥% ផ្នែកតបណ្ដាញកាំមេរាសុវត្ថិភាពមានចំនួនសិស្ស៧នាក់បានបញ្ចប់ សិស្សដែលធ្វើការត្រូវជំនាញមានចំនួន៧នាក់ ស្មើនឹង ៧.៣៧% ក្នុងចំណោមសិស្សទាំងអស់ដែលបានបញ្ចប់ គិតជាភាគរយមានចំនួនស្មើនឹង ២២.១១%ពួកគាត់ធ្វើការតាមតាមផ្នែកផ្សេងៗ ។

ជារួមសិស្សដែលធ្វើការត្រូវជំនាញស្មើនឹង ៥៣.៦៨%នៃចំនួនសិស្សសរុបទាំងអស់ដែលបានបញ្ចប់ ហើយសិស្សដែលធ្វើការខុសជំនាញស្មើនឹង ១២.៦៤%នៃចំនួនសិស្សសរុបដែលបានបញ្ចប់ សិស្សអត់ការងារធ្វើស្មើនឹង ២.១% នៃចំនួនសិស្សសរុបដែលបានបញ្ចប់ ចំណែក៨.៤៣%នៃចំនួនសិស្សដែលបានបញ្ចប់ការសិក្សាដែលបើកអាជីវកម្មខ្លួនឯងផ្ទាល់៕

## ១.២. គម្រោង លើកកម្ពស់ការអប់រំ និងការងារនៅកម្ពុជា (STRENGTHENING EDUCATION & EMPLOYABILITY IN KAMPUCHEAN PROJECT (SEEK)៖

**ក. តំបន់គោលដៅ** ៖ គម្រោងនេះកំពុងអនុវត្តន៍ទៅលើបីខេត្តរួមមាន ខេត្តកំពង់ចាម ខេត្តត្បូងឃ្មុំ និងខេត្តកំពង់ឆ្នាំង ។

**ខ. រយៈពេល** ៖ ១ឆ្នាំ (ថ្ងៃទី១ ខែមករា ឆ្នាំ២០២០ ដល់ ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២០)

**គ. ថវិកាក្នុងឆ្នាំ២០២០** ៖ ចំនួន ៧៩,០០០.០០ ដុល្លាអាមេរិក

**ឃ. សកម្មភាពសំខាន់ៗ** ៖ នៅតាមខេត្តនីមួយ គម្រោងបានជ្រើសរើសស្រុកធ្វើជាគោលដៅដើម្បីអនុវត្តន៍សកម្មភាពរបស់ខ្លួន ដែលមានដូចជា៖

- ខេត្តកំពង់ចាម បានជ្រើសរើសស្រុកកំពង់សៀម ធ្វើជាស្រុកគោលដៅ ហើយឃុំចំនួន៥ ត្រូវបានចូលអនុវត្តគម្រោងនៅទីនោះ។ ក្នុងនោះមានឃុំ ទ្រាន ឃុំរអាង ឃុំអំពិល ឃុំកោះរកា និងឃុំគគរ។
- ខេត្តកំពង់ឆ្នាំង បានជ្រើសរើសស្រុក រលាប្អៀរ ហើយឃុំដែលបានចូលអនុវត្តមាន ឃុំរលាប្អៀរ ឃុំគោកបន្ទាយ និងឃុំជើងគ្រាវ។
- ខេត្តត្បូងឃ្មុំ បានជ្រើសរើសស្រុកត្បូងឃ្មុំ និងស្រុកក្រូចឆ្មា ធ្វើជាស្រុកគោលដៅ ក្នុងនោះមានឃុំចំនួន៥នៅក្នុងស្រុកត្បូងឃ្មុំ និង១ឃុំនៅក្នុងស្រុកក្រូចឆ្មា ដែលបានចូលអនុវត្តសកម្មភាពរបស់ខ្លួន គឺមាន ឃុំទន្លេបិទ ឃុំជីរោទិ៍១ ឃុំជីរោទិ៍២ ឃុំបឹងប្រួល និងឃុំពាមជីលាំង និងឃុំទ្រាស ក្នុងស្រុកក្រូចឆ្មា។

**ង. សកម្មភាពសំខាន់ៗ ដែលគម្រោងបានអនុវត្តន៍នៅក្នុងឆ្នាំ២០២០ រួមមាន៖**

១. កសាងទំណាក់ជាមួយអាជ្ញាធរ អ្នកមានសមត្ថកិច្ច និងអ្នកពាក់ព័ន្ធនានា
២. ប្រជុំតំរង់ទិស និងការផ្សព្វផ្សាយអំពីគម្រោងលើកកម្ពស់ការអប់រំ និងការងារនៅកម្ពុជា។
៣. ចងក្រងបង្កើតក្រុមកុមារយុវជន (ក្រុមសិក្សាស្រាវជ្រាវ ដែលមានការចូលរួម)នៅថ្នាក់ភូមិ។
៤. ផ្តល់វគ្គបណ្តុះបណ្តាលកសាងសមត្ថភាព និងគាំទ្របច្ចេកទេសដល់ក្រុមកុមារយុវជន អនុវត្តសកម្មភាពសិក្សាស្រាវជ្រាវសកម្មភាពដែលមានការចូលរួម។
៥. រៀបចំសិក្ខាសាលាជាមួយអ្នកពាក់ព័ន្ធនៅកំរិតថ្នាក់ឃុំ (ជាមួយក្រុមជួយខ្លួនឯង និងគកនក)។
៦. បង្កើតប្រព័ន្ធវៃឆ្លាត ដែលហៅថា កម្មវិធីត្រីវិស័យ

៧. និងការបង្កើតមណ្ឌលប្រឹក្សាយោបល់អាជីព ។

**១. ចំនួនអ្នកទទួលផលសរុប ពីការអនុវត្តគម្រោង ក្នុងឆ្នាំទី១នេះ មាន៖**

| ប្រភេទអ្នកទទួលផល | អ្នកទទួលផលសរុប | | ជនជាតិខ្មែរ | | ជនជាតិចាម | |
|---|---|---|---|---|---|---|
| | សរុប | ស្រ្តី | សរុប | ស្រ្តី | សរុប | ស្រ្តី |
| សហគមន៍ និងអ្នកពាក់ព័ន្ធ | ៧១៦ | ៣៧១ | ៥៨៧ | ៣០៧ | ១២៩ | ៦៤ |
| កុមារយុវជនក្នុងសាលា | ៩៨៥ | ៦៣៦ | ៨៣៤ | ៥២៤ | ១៥១ | ១១២ |
| យុវជនក្រៅសាលា | ២៩៤ | ១៣៦ | ១៩១ | ៩២ | ១០៣ | ៤៤ |
| សរុប៖ | ១,៩៩៥ | ១,១៤៣ | ១,៦១២ | ៩២៣ | ៣៨៣ | ២២០ |

**សមិទ្ធិផល ដែលសម្រេចបាន តាមសកម្មភាពនីមួយៗ៖**

**១. គោលបំណងគម្រោង៖** ចូលរួមចំណែកក្នុងការធានាការអប់រំបញ្ចូលគ្នា និងឱកាសការងារ ធ្វើអោយមានភាពប្រសើរឡើងសម្រាប់យុវជនកម្ពុជាក្នុងគ្រប់ទិដ្ឋភាពទាំងអស់ ដែលរំពឹងទុកនៅក្នុង SDG4 និងSDG8 ៕

- SDG4: គុណភាពអប់រំប្រកបដោយសមធម៌ និងបរិយាប័ន្ន
  - SDG4.1: (ធានាថាក្មេងស្រីនិងក្មេងប្រុសទាំងអស់បានបញ្ចប់ការសិក្សាបឋមសិក្សានិងមធ្យមសិក្សាដោយឥតគិតថ្លៃមានសមធម៌ និងគុណភាព ដែលនាំឱ្យមានលទ្ធផលសិក្សា ដែលពាក់ព័ន្ធនិងមានប្រសិទ្ធភាព) ។
- SDG8: កំណើនសេដ្ឋកិច្ចប្រកបដោយចីរភាពនិងបរិយប័ន្ន
  - SDG8. 5: (ការទទួលបានការងារនិងការងារសមរម្យសម្រាប់ទាំងអស់គ្នា)
  - SDG8. 6: (ការកាត់បន្ថយសមាមាត្រនៃយុវជនមិនស្ថិតនៅក្នុងការងារ ការអប់រំ ឬការបណ្តុះបណ្តាល)

**២. សកម្មភាពទី១៖** ការករសាងទំនាក់ទំនងជាមួយអាជ្ញាធរ និងអ្នកពាក់ព័ន្ធនានាក្នុងការអនុវត្តសកម្មភាព



នៅដើមឆ្នាំ២០២០ អំឡុងខែមិនា និងមេសា ជាការចាប់ផ្តើមអនុវត្តន៍ សកម្មភាពគម្រោងបុគ្គលិកបានចុះជួបសំណេះសំណាល ពិគ្រោះ យោបល់លើសកម្មភាពគម្រោងសំខាន់ៗ និងស្នើសុំកិច្ចសហការណ៍ពីមន្ទីរ ការិយាល័យអាជ្ញាធរ និងអ្នកពាក់ព័ន្ធដើម្បីជាការបង្ករភាពងាយស្រួលដល់ការអនុវត្តសកម្មភាពគម្រោងរបស់បុគ្គលិកផងដែរ។

## ២.១. សកម្មភាពទី២៖ ការទំនាក់ទំនង និងការផ្សព្វផ្សាយអំពីការអនុវត្តគម្រោង៖




ជាក់ស្តែងក្នុងការអនុវត្តគម្រោងនៅក្នុងឆ្នាំទី១នេះ គម្រោងបានធ្វើការទំនាក់ទំនង និងសហការយ៉ាងជិតស្និតជាមួយអាជ្ញាធរមូលដ្ឋាន ភូមិ ឃុំ ស្រុក ខេត្ត សហគមន៍ និងអ្នកដឹកនាំសាសនា ក្នុងគោលបំណងដើម្បីផ្សព្វផ្សាយគម្រោងដល់ក្រុមគោលដៅឲ្យបានយល់ និងដើម្បីបង្ករភាពងាយស្រួលផងដែរក្នុងការអនុវត្តសកម្មភាពរបស់ខ្លួនក្នុងតំបន់គោលដៅនៃខេត្តទាំងបី គឺខេត្តកំពង់ចាម ខេត្តត្បូងឃ្មុំ និងខេត្តកំពង់ឆ្នាំង ៕

### លទ្ធផលដែលមានចូលរួមក្នុងការផ្សព្វផ្សាយគម្រោងដូចមានក្នុងតារាងខាងក្រោមនេះ៖

| ប្រភេទអ្នកទទួលផល | អ្នកទទួលផលសរុប | | ជនជាតិខ្មែរ | | ជនជាតិចាម | |
|---|---|---|---|---|---|---|
| | សរុប | ស្ត្រី | សរុប | ស្ត្រី | សរុប | ស្ត្រី |
| អាជ្ញាធរភូមិឃុំ និងគកនក | ១៤៧ | ២៩ | ១៤៦ | ២៩ | ១ | ០ |
| ក្រុមជួយខ្លួនឯង ឬក្រុមសន្សំ | ៦៣ | ៤៦ | ៤៩ | ៣៧ | ១៤ | ៩ |
| អ្នកសហគមន៍ (សាសនា...) | ៣៩០ | ២៣៦ | ២៩៦ | ១៨៨ | ៩៤ | ៤៨ |
| កុមារយុវជន | ៧០២ | ៣៩៧ | ៥៨៤ | ៣២៩ | ១១៨ | ៦៨ |
| សរុប៖ | ១,៣០២ | ៧០៨ | ១,០៧៥ | ៥៨៥ | ២២១ | ១២៥ |

## ២.២. សកម្មភាពទី៣៖ ការចងក្រងក្រុមកុមារយុវជននៅតាមឃុំគោលដៅ៖



ក្រោយពីមានការទំនាក់ទំនង និងការផ្សព្វផ្សាយគម្រោងដល់អ្នកពាក់ព័ន្ធឲ្យបានយល់ពីអត្ថន័យគម្រោង គោលបំណង សារៈសំខាន់ និងក្រុមគោលដៅរបស់គម្រោងរួចហើយ បុគ្គលិកគម្រោងក៏បានសហការណ៍ជាមួយគកនកតាមឃុំគោលដៅ រៀបចំការប្រជុំ និងចងក្រងយុវជនជាក្រុមដើម្បីជុំរុញ និងលើកទឹកចិត្តពួកឲ្យបានចូលរួមក្នុងដំណើរអភិវឌ្ឍន៍សង្គម និងសិក្សាស្រាវជ្រាវដោយក្រុមពួកគេផ្ទាល់លើប្រធានបទ "ឧបសគ្គចំពោះភាពមានការងារធ្វើ និងលទ្ធភាពធនធានសេដ្ឋកិច្ចរបស់យុវជន" ។ ក្រុមគោលដៅ នៃក្រុមកុមារយុវជនគឺ ផ្តោតលើយុវជនទាំងក្នុងសាលា និងក្រៅសាលា ដែលមានអាយុចន្លោះពី ១៥ឆ្នាំ ទៅ ៣០ឆ្នាំ ។ ដូចនេះ បុគ្គលិកគម្រោងបានសហការណ៍យ៉ាងល្អជាមួយភូមិឃុំ ជាពិសេសគកនក និងអ្នកដឹកនាំសាសនា ដើម្បី

កំណត់អត្តសញ្ញាណ និងជ្រើសរើសយុវជនស្ម័គ្រចិត្តចូលរួមរៀនសូត្រជាមួយគម្រោង ដើម្បីជាឱកាសក្នុងការអភិវឌ្ឍន៍ចំណេះដឹង និងសមត្ថភាពរបស់ពួកគេដើម្បីឈានរកឱកាសការងារដ៏សមស្របមួយនាពេលអនាគត។

**លទ្ធផល យុវជនដែលបានចុះឈ្មោះចូលរួមក្នុងក្រុមយុវជនដូចមានក្នុងតារាងខាងក្រោមនេះ៖**

| ខេត្ត | ចំនួនក្រុមយុវជន | អ្នកទទួលផលសរុប | | ជនជាតិខ្មែរ | | ជនជាតិចាម | |
|---|---|---|---|---|---|---|---|
| | | សរុប | ស្ត្រី | សរុប | ស្ត្រី | សរុប | ស្ត្រី |
| ខេត្តកំពង់ចាម | ៧ | ១៤៨ | ៨៤ | ១៣៩ | ៨០ | ៩ | ៤ |
| ខេត្តត្បូងឃ្មុំ | ៧ | ១៤០ | ៨៤ | ៩៧ | ៥៧ | ៤៣ | ២៧ |
| ខេត្តកំពង់ឆ្នាំង | ៧ | ១៤៨ | ៨៨ | ១៤៨ | ៨៨ | ០ | ០ |
| សរុប៖ | ២១ | ៤៣៦ | ២៥៦ | ៣៨៤ | ២២៥ | ៥២ | ៣១ |

## ២.៣. សកម្មភាពទី៤៖ ការបណ្តុះបណ្តាលពង្រឹងសមត្ថភាពដល់ក្រុមកុមារយុវជន៖





ក្រោយពី ការចងក្រងជាក្រុម យុវជនទាំងអស់ត្រូវបានចូលរួមប្រជុំបង្កើតរចនាសម្ព័ន្ធ និងតំរង់ទិសពីគម្រោងលើកកម្ពស់ការអប់រំ និងការងារនៅកម្ពុជា ។ យុវជនទាំងអស់ក៏ត្រូវបានបណ្តុះបណ្តាល ពីជំនាញទន់មួយចំនួនផងដែរដើម្បីលើកទឹកចិត្ត និងលើកកម្ពស់ការចូលរួមរបស់ពួកគេ ។ ជំនាញដែលពួកគេទទួលបានមានដូចជា ជំនាញអភិវឌ្ឍន៍ខ្លួនឯង ការគ្រប់គ្រងពេលវេលា ការប្រឹក្សាអាជីព និងការតំរង់ទិសកម្មវិធីត្រីវិស័យ។

លទ្ធផល យុវជនដែលបានចូលរួមវគ្គបណ្តុះបណ្តាលពង្រឹងសមត្ថភាពដូចមានក្នុងតារាងខាងក្រោមនេះ៖

| ប្រភេទអ្នកទទួលផល | អ្នកទទួលផលសរុប | | ជនជាតិខ្មែរ | | ជនជាតិចាម | |
|---|---|---|---|---|---|---|
| | សរុប | ស្ត្រី | សរុប | ស្ត្រី | សរុប | ស្ត្រី |
| យុវជនក្រៅសាលា | ២៧៤ | ១៩៨ | ២៣៦ | ១៦៨ | ៣៨ | ៣០ |
| យុវជនក្នុងសាលា | ៣៤ | ១៦ | ១៥ | ៨ | ១៩ | ៨ |
| សរុប៖ | ៣០៨ | ២១៤ | ២៥១ | ១៧៦ | ៥៧ | ៣៨ |

លើសពីនេះ យុវជនដែលជាអ្នកដឹកនាំក្រុមកុមារយុវជនទាំង១៧ក្រុម ត្រូវបានទទួលការបណ្តុះបណ្តាល និងគាំទ្របច្ចេកទេសស្តីពីការស្រាវជ្រាវសកម្មភាពដែលមានការចូលរួម។

| ប្រភេទអ្នកទទួលផល | អ្នកទទួលផលសរុប | | ជនជាតិខ្មែរ | | ជនជាតិចាម | |
|---|---|---|---|---|---|---|
| | សរុប | ស្ត្រី | សរុប | ស្ត្រី | សរុប | ស្ត្រី |
| យុវជនក្រៅសាលា | ៥២ | ៤១ | ៤៧ | ៣៧ | ៥ | ៤ |
| យុវជនក្នុងសាលា | ១០ | ៩ | ៧ | ៧ | ៣ | ២ |
| សរុប៖ | ៦២ | ៥០ | ៥៤ | ៤៤ | ៨ | ៦ |





## ២.៤. សកម្មភាពទី៥៖ ការគាំទ្រយុវជន ប្រមូលទិន្នន័យ វិភាគទិន្នន័យ ធ្វើរបាយស្រាវជ្រាវ និងធ្វើសិក្ខាសាលាពិគ្រោះយោបល់នៅកំរិតថ្នាក់ឃុំ៖



យុវជនអ្នកដឹកនាំក្លឹបយុវជនទាំង៦២ ក្រោយពីទទួលបានការបណ្តុះបណ្តាលក្នុងខែតុលា២០២១ ពួកគេក៏បានរៀបចំការប្រជុំក្រុមរបស់ពួកគេ ដើម្បីផ្ទេរចំណេះដឹង និងគំរង់ទិសក្រុមស្តីពីដំណើរការចុះប្រមូលទិន្នន័យនៅតាមខ្នងផ្ទះស្របតាមផែនទីដែលបានគូររួចនៅក្នុងខែវិច្ឆិកា ។ នៅតាមភូមិនីមួយៗ ត្រូវបានកំណត់សំណាកពីចំនួន៣០ទៅ៤០នាក់។ សម្រាប់ដំណើរការចុះប្រមូលទិន្នន័យតាមភូមិ ដែលកំណត់នីមួយ ៗ គឺពួកគេប្រើពេលវេលាអស់ប្រមាណជាពី២០ថ្ងៃ ទៅ៣០ថ្ងៃ សម្រាប់នីមួយៗ។



ក្រោយពីការប្រមូលទិន្នន័យរួចរាល់ ពួកគេត្រូវបានបណ្តុះបណ្តាល និងសម្របសម្រួលក្នុងដំណើរការវិភាគទិន្នន័យ និងធ្វើរបាយការណ៍ស្រាវជ្រាវ និងរៀបចំស្លាយបទបង្ហាញ សម្រាប់ការធ្វើបទបង្ហាញនៅកំរិតថ្នាក់ឃុំ ដែលមានអាជ្ញាធរភូមិឃុំ និងអ្នកពាក់ព័ន្ធផ្សេងៗចូលរួមផងដែរ។

## ២.៥. សកម្មភាពទី៦៖ ការរៀបសិក្ខាសាលាជាមួយអ្នកពាក់ព័ន្ធនៅថ្នាក់ឃុំ (ជាមួយភូមិឃុំ និងក្រុមជួយខ្លួន ឬក្រុមសន្សំប្រាក់នានា)៖





ដើម្បីលើកម្ពស់ការចូលរួម និងការមកប្រើប្រាស់មណ្ឌលលើកកម្ពស់ការអប់រំ និងការងារនៅកម្ពុជា គម្រោងបានសហការណ៍ជាមួយអង្គការដៃគូ គឺ អង្គការ ខេប អង្គការក្រុមប្រឹក្សាកុមារកម្ពុជា និងអង្គការ វីរើលជីវីស៊ី ក្នុងការរៀបចំសិក្ខាសាលាតំរង់ទិស ផ្សព្វផ្សាយ និងកៀរការចូលរួម និងគាំទ្រដើម្បីលើកទឹកចិត្ត និងផ្តល់អំណាចដល់អ្នកពាក់ព័ន្ធដើម្បីជំរុញ និងផ្តល់ឪកាសដល់យុវជន ដើម្បីបានចូលរួមជាមួយសកម្មភាពគម្រោង ។

ជាពិសេស ដើម្បីផ្តល់អំណាចដល់សង្គមស៊ីវិល និងសហគមន៍មូលដ្ឋាន ក្នុងពង្រឹងតួនាទីចូលរួម និងបញ្ជូនយុវជនទៅរកសេវាបណ្តុះបណ្តាលវិជ្ជាជីវៈ និងប្រើប្រាស់មណ្ឌលប្រឹក្សាអាជីព ក្នុងគោលបំណងតំរង់ទិសអំពីការងារ និងការអប់រំរបស់ផងគេ ។

**លទ្ធផល អ្នកពាក់ព័ន្ធ ដែលបានចូលរួមក្នុងសកម្មភាពដូចមានក្នុងតារាងខាងក្រោមនេះ៖**

| ប្រភេទអ្នកទទួលផល | អ្នកទទួលផលសរុប | | ជនជាតិខ្មែរ | | ជនជាតិចាម | |
|---|---|---|---|---|---|---|
| | សរុប | ស្រ្តី | សរុប | ស្រ្តី | សរុប | ស្រ្តី |
| ក្រុមជួយខ្លួនឯង ឬក្រុមសន្សំ | ៤៧ | ៣៧ | ៤៧ | ៣៧ | ០ | ០ |
| សមាជិកគនកន | ៤០ | ៨ | ៣៨ | ៨ | ២ | ០ |
| យុវជន | ៥ | ៥ | ៥ | ៥ | ០ | ០ |
| **សរុប៖** | **៩២** | **៥០** | **៩០** | **៥០** | **២** | **០** |

## ២.៦. សកម្មភាពទី៧៖ ការបង្កើតប្រព័ន្ធវៃឆ្លាត (កម្មវិធីត្រីវិស័យ)៖




នៅក្នុងត្រីមាសទី៣នៃឆ្នាំសារពើពន្ធនេះ គម្រោងបានធ្វើការសហការណ៍ជាមួយអង្គការដៃគូ និងធ្វើការដេញថ្លៃជ្រើសរើសស្ថាប័នឯកទេសបង្កើតកម្មវិធីត្រីវិស័យ (Trey Visay App) ។ ក្នុងពេលនោះ យើងជ្រើសបានស្ថាប័នឯកទេសដែលជាដៃគូជាមួយ គឺអង្គការ InSTEED ដែលមានការិយាល័យនៅទីក្រុងភ្នំពេញ ឲ្យរៀបចំ និងធ្វើបច្ចុប្បន្នភាពមាតិកានានាដែលមានក្នុងកម្មវិថីត្រីវិស័យ។ កម្មវិធីត្រីវិស័យគឺជាកម្មវិធីមួយ ដែលអនុញ្ញាតិឲ្យកុមារយុវជនបានប្រើប្រាស់ ក្នុងគោលបំណងពង្រឹងនិងពង្រីកចំណេះដឹងសម្រាប់ការសិក្សារ និងការស្វែងរកការងារធ្វើរបស់ផងគេ ។

### មាតិការដែលបានដាក់ក្នុងកម្មវិធីត្រីវិស័យនោះមានដូចជា៖

- **វាយតម្លៃមុខរបរ៖** គឺការធ្វើតេស្តមុខរបរ ឬអាជីពដោយផ្អែកលើបុគ្គលិកលក្ខណៈដើម្បីជ្រើសរើសមុខរបរដែលសាកសមនឹងអ្នក។
- **ល្បែងយល់អំពីបុគ្គលិកលក្ខណៈ៖** គឺការធ្វើតេស្តល្បែងយល់អំពីបុគ្គលិកលក្ខណៈ។
- **គ្រឹះស្ថានសិក្សា៖** អំពីព័ត៌មានគ្រឹះសិក្សា អាសយដ្ឋានទំនាក់ទំនង និងមុខវិជ្ជាសិក្សារក្រោយបញ្ចប់ថ្នាក់ទី ១២ ។
- **ប្រភេទការងារ៖** សម្រាប់អ្នកគ្មានលទ្ធភាពបន្តការសិក្សាបរិញ្ញាបត្រ អ្នកអាចរៀនជំនាញវិជ្ជាជីវៈរយៈពេលខ្លី។
- **វីដេអូមុខរបរ៖** អ្នកអាចយល់ដឹងអំពីមុខរបរ និងអាជីពតាមរយៈវីដេអូនេះ។
- **មជ្ឈមណ្ឌលការងារ៖** អ្នកនឹងយល់ដឹងអំពីការងារ កម្លាំងពលកម្ម និងព័ត៌មានទីផ្សារការងារ។

ជាលទ្ធផល ក្រោយពីកម្មវិធីត្រីវិស័យនេះដំឡើងរួចនៅក្នុងខែវិច្ឆិកា ឆ្នាំ២០២០ បុគ្គលិកគម្រោងបានកត់សម្គាល់ និងកត់ត្រានូវកំរិតពេញចិត្តក្នុងការប្រើប្រាស់កម្មវិធីនេះផងដែរ ។ ៧០% ក្នុងចំណោម ១៨១នាក់ បានរាយការណ៍ថា ពួកគេសប្បាយចិត្ត និងពេញចិត្តដែលបានឃើញ និងបានប្រើប្រាស់កម្មវិថីត្រីវិស័យនេះ។

ប្អូន **សេង រក្សា** សិស្សថ្នាក់ទី១២ នៅវិទ្យាល័យតាមាង បាននិយាយថា " ខ្ញុំមានអារម្មណ៍រំភើប និងសប្បាយចិត្តដែលបានចូលរួមសកម្មភាពជាមួយគម្រោង លើកកម្ពស់ការអប់រំ និងការងារនៅកម្ពុជា ដែលអនុវត្តន៍ដោយអង្គការសកម្មភាពព្រះពុទ្ធសាសានាដើម្បីអភិវឌ្ឍន៍សង្គម (BSDA) និងអង្គការក្រុមប្រឹក្សាយុវជនកម្ពុជា (YCC) ។ ខ្ញុំមានតួនាទីជាប្រធានក្លឹមយុវជនក្នុងឃុំកោះរកា។ ខ្ញុំបានចូលរួម និងទទួលវគ្គបណ្ដុះបណ្ដាលជាពីអង្គការ BSDA និង អង្គការ YCC ជាច្រើនដូចជាវគ្គ ការចងក្រងក្រុមមិត្តអប់រំមិត្ត ការអភិវឌ្ឍខ្លួនឯង ជំនាញតស៊ូមតិ ការតំរង់ទិសអាជីព និងការប្រើប្រើសកម្មវិធីត្រីវិស័យ ។ លើសពីនេះ ខ្ញុំបានចូលរួមដឹកនាំក្រុមយុវជនឃុំ ចុះប្រមូលទិន្នន័យ វិភាគទិន្នន័យ និងចងក្រងជារបាយការណ៍សម្រាប់ធ្វើបទបង្ហាញដល់អ្នកពាក់ព័ន្ធនៅថ្នាក់ឃុំផងដែរ។ ជំនាញទាំងនេះបានធ្វើឲ្យខ្ញុំមានភាពរឹងមាំគ្រប់គ្រានក្នុងសាងសមត្ថភាពខ្លួន និងស្វែងរកការងារដ៏សមស្របមួយបន្ទាប់ពីការបញ្ចប់ការសិក្សារបស់នាងខ្ញុំ។

## ២.៧. សកម្មភាពទី ៨៖ ការកែរលម្អមណ្ឌលប្រឹក្សាយោបល់អាជីព៖

ក្នុងដំណើរការតម្លើងមណ្ឌលប្រឹក្សាយោបល់អាជីព គម្រោងលើកកម្ពស់ការអប់រំ និងការងារនៅកម្ពុជា ហៅថា (គម្រោងស៊ីក) បានធ្វើការទំនាក់ទំនងមន្ទីរ និងការិយាល័យអប់រំ យុវជន និងកីឡា និងនាយកសាលាវិទ្យាល័យជាច្រើន ដើម្បីសិក្សាលើស្ថិតិសិស្ស ប្រជាសាស្ត្រ និងតំបន់ដែលមានជនជាតិភាគតិច (ខ្មែរឥស្លាម) រស់នៅច្រើន ដើម្បីឆ្លើយតបទៅនឹងសូចនាករ និងតម្រូវការរបស់គម្រោង។





ក្រោយពីទំនាក់ទំនង និងសិក្សាឈ្វេងយល់រួចហើយ គម្រោងបានសម្រេចដាក់ទីតាំងដូចខាងក្រោម៖

- សម្រាប់ខេត្តកំពង់ចាម គឺដាក់នៅក្នុង វិទ្យាស្ថាននៃក្តីញញឹម (ជាវិទ្យាស្ថានបណ្តុះបណ្តាលជំនាញវិជ្ជាជីវៈរបស់អង្គការ សកម្មភាពព្រះពុទ្ធសាសនាដើម្បីអភិវឌ្ឍន៍សង្គម ដែលហៅកាត់ថា (BSDA)) ស្ថិតក្នុងភូមិអំពិលលើ ឃុំអំពិល ស្រុកកំពង់សៀម ខេត្តកំពង់ចាម។
- សម្រាប់ខេត្តត្បូងឃ្មុំ គឺដាក់នៅក្នុងសាលាវិទ្យាល័យ ហ៊ុន សែន ពាមជីលាំង ស្ថិតនៅក្នុងភូមិចន្លុះលិច ឃុំពាមជីលាំង ស្រុកត្បូងឃ្មុំ ខេត្តត្បូងឃ្មុំ។
- សម្រាប់ខេត្តកំពង់ឆ្នាំង គឺដាក់នៅក្នុងសាលាវិទ្យាល័យ ប៊ុនរ៉ានី ហ៊ុន សែន រលាប្អៀរ ស្ថិតនៅក្នុងភូមិស្លកវាជ្យ ឃុំអណ្តូងស្នាយ ស្រុករលាប្អៀរ ខេត្តកំពង់ឆ្នាំង។

### ដោយឡែក សម្រាប់សេវាកម្មមណ្ឌលស៊ីក ដែលយុវជនអាចចូលមកប្រើប្រាស់រួមមាន៖

- ការប្រើប្រាស់បណ្ណាល័យ (អានទូវជំនាញអ្នកដឹកនាំ អ្នកសហគ្រិនភាព និងគន្លឹះជោគជ័យផ្សេងៗ)
- ការប្រើប្រាស់កុំព្យូទ័រ និងថៃប្លេត (សម្រាប់គោលបំណងស្វែងរកការងារ និងការសិក្សានានា)
- ការប្រឹក្សាយោបល់អាជីព
- ការសិក្សាជំនាញទន់
- និងការសិក្សាស្រាវជ្រាវដែលមានការចូលរួម

## ៣.បញ្ហាប្រឈម និងដំណោះស្រាយ៖

| បញ្ហាប្រឈម | ដំណោះស្រាយ |
|---|---|
| ▪ ដោយសារស្ថានភាព កូវីដ-១៩ គម្រោងមិនអាចសម្រេចបានគ្រប់សកម្មភាពតាមផែនការគ្រោង។ ឱ. សកម្មភាពផ្តល់វគ្គបណ្តុះបណ្តាល ពង្រឹងសមត្ថភាពសង្គមស៊ីវិល និងផ្តល់កញ្ចប់ថវិកា (Sub-Grant) និងសកម្មភាពសិក្ខាសាលាពិគ្រោះយោបល់ ថ្នាក់ឃុំ និងថ្នាក់ខេត្ត ។ | ▪ សកម្មភាពដែលមិនបានអនុវត្តន៍ត្រូវបានលើកយកទៅអនុវត្តន៍នៅឆ្នាំបន្ទាប់<br>▪ រៀបចំគោលការណ៍ណែនាំ និង ToR នានាឲ្យរួចជាស្រេច ។<br>▪ កសាងទំនាក់ទំនង និងដាក់លិខិតស្នើទៅកាន់អ្នកពាក់ព័ន្ធរួចជាស្រេច ។ |
| ▪ គម្រោងពិបាក់ស្វែងរក និងជ្រើសរើសយុវជនក្រៅសាលាចូលរួមក្លឹបកុមារយុវជន និងចូលរួមជាមួយ | ▪ សហការណ៍យ៉ាងជិតស្និតជាមួយអាជ្ញាធរភូមិឃុំ និង គកនក ក្នុងការកំណត់អត្តសញ្ញាណយុវជន |

| | |
|---|---|
| សកម្មភាពគម្រោង ។ | ក្រៅសាលា និង ជ្រើសរើសពួកគេឲ្យចូលរួមក្នុងសកម្មភាពគម្រោង។ |
| ▪ សមត្ថភាព និងបច្ចេកទេសបុគ្គលិកនៅមានកំរិតក្នុងការប្រើប្រាសប្រព័ន្ធបណ្តាញសង្គម ។ | ▪ បុគ្គលិកគម្រោងព្យាយាមទំនាក់ទំនង ស្វែងរកការគាំទ្រពីអ្នកបច្ចេកទេស និងវគ្គបណ្តុះបណ្តាល់ផ្សេងៗ ជាជំនួយ និងពង្រឹងសមត្ថភាពរបស់ផងគេ ។ |

## ៤.សំណូមពរះ

- សុំអោយអាជ្ញាធរដែនដីមាតាបិតានិងដៃគូរពាក់ព័ន្ធយកចិត្តទុកដាក់ពីបញ្ហាកុមារយុវជននិងស្វែងរកដំណោះស្រាយរួមគ្នា ។
- ទាំងអាជ្ញាធរ សហគមន៍មូលដ្ឋាន និងសង្គមស៊ីវិល កំណត់អត្តសញ្ញាណយុវជនក្រៅសាលា និងបញ្ជូនពួគេទៅរកសេវាបណ្តុះបណ្តាលវិជ្ជាជីវៈទាំងរបស់រដ្ឋ របស់អង្គការសង្គមស៊ីវិលនានាដែលមាននៅក្នុងខេត្ត និងជាពិសេសបញ្ជូនពួកគេទៅប្រើប្រាស់មណ្ឌលប្រឹក្សាយោបល់អាជីព ដើម្បីលើកទឹកចិត្តពួកគេឲ្យទទួលបានការងារដ៏សមស្របមួយ។

## ៥. ផែនការសម្រាប់ឆ្នាំបន្ទាប់៖

- រក្សាការទំនាក់ទំនងជិតស្និតជាមួយមន្ទីរ ការិយាល័យអប់រំ យុវជន និងកីឡា មន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ មជ្ឈមណ្ឌលពហុបច្ចេកវិទ្យាខេត្ត និងមជ្ឈមណ្ឌលការងារ ព្រមទាំងអាជ្ញាធរ មូលដ្ឋាន នាយកសាលា និងគគនក ដើម្បីលើកទឹកចិត្តកុមារយុវជនបានមកប្រើប្រាស់មណ្ឌលប្រឹក្សាយោបល់អាជីព និងចូលរួមជាមួយសកម្មភាពគម្រោងស៊ីក។
- សហការណ៍ជាមួយអង្គការដៃគូផ្តល់វគ្គបណ្តុះបណ្តាលពង្រឹងសមត្ថភាពសង្គមស៊ីវិល និងអង្គការសហគមន៍តូចៗក្នុងគោលបំណងគាំទ្រកញ្ចប់ថវិកា (Sub-Grant) ដើម្បីផ្តល់អំណាចពួកគេក្នុងការកៀរគរយុវជនក្រៅសាលាឲ្យទទួលបានការបណ្តុះបណ្តាលវិជ្ជាជីវៈ និងទទួលបានការងារសមស្របមួយ។
- ពង្រីកចំនួនក្រុមក្លឹបកុមារយុវជនពីចំនួន២១ក្លឹប ទៅ ចំនួន៥០ក្លឹប ក្នុង ៣ខេត្តគោលដៅ។
- បណ្តុះបណ្តាល និងគាំទ្របច្ចេកទេសយុវជនក្នុងដំណើរការសិក្សាស្រាវជ្រាវដែលមានការចូលរួម ការចងក្រងរបាយការណ៍ស្រាវជ្រាវ និងការរៀបចំសិក្ខាសាលាពិគ្រោះយោបល់នៅកំរិតថ្នាក់ឃុំ និងថ្នាក់ខេត្ត។

## ១.៣. គម្រោង អប់រំអនាគតកុមារ (CHILD'S FUTURE EDUCATION PROJECT)៖

**ក. ទីកន្លែង** ៖ ស្រុកបាកាន តាលោសែនជ័យ និងស្រុកភ្នំក្រវាញ ខេត្តពោធិ៍សាត់ (សាលាបឋមសិក្សាចំនួន១៩ និង ២៤ភូមិ)

**ខ. ចំនួនបុគ្គលិក** ៖ ៤ នាក់ (ស្រី២នាក់)

**គ. រយៈពេល** ៖ ១ឆ្នាំ (ថ្ងៃទី១ ខែមករា ដល់ ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២០)

**ឃ. ថវិកាអនុវត្តន៍គម្រោង** ៖ ៤៥,៥៩០ ដុល្លាអាមេរិក

### ១. ចំនួនអ្នកទទួលផលសរុបពីគម្រោង ដែលបានអនុវត្តន៍នៅក្នុងឆ្នាំ២០២០៖

| អ្នកទទួលផលសរុប | អាយុក្រោម១៨ | | អាយុលើស១៨ | |
|---|---|---|---|---|
| | សរុប | ស្ត្រី | សរុប | ស្ត្រី |
| សិស្ស | ៤,០២០ | ២,០៩៧ | 0 | 0 |
| ក្លឹបកុមារ/យុវជន | ៤៩២ | ២៦៥ | 0 | 0 |
| អជ្ញាធរពាក់ព័ន្ធ | 0 | 0 | ៤៥ | ១៥ |
| ដៃគូអប់រំ | 0 | 0 | ១៣៩ | ៤៧ |
| Total៖ | ៤,៥១២ | ២,៣៦២ | ១៨៤ | ៦២ |

### ២. សមិទ្ធផលដែលសម្រេចបានពីការអនុវត្តគម្រោងរួមមាន៖

- **សកម្មភាពទី១៖** គាំទ្រក្រុមបំប៉ន និងពិនិត្យតាមដាន នៃការិយាល័យអប់រំយុវជន និងកីឡាស្រុក ដើម្បីធ្វើការតាមដាន និងវាយតម្លៃលើការងាររបស់សាលារៀនចំនួន១៩សាលាគោលដៅ (៦សាលានៅស្រុកភ្នំក្រ វាញ ៤សាលានៅស្រុកតាលោសែនជ័យ និង៩សាលានៅស្រុកបាកាន) ។
  - គាំទ្រក្រុមបំប៉ន និងពិនិត្យតាមដាន នៃការិយាល័យអប់រំយុវជន និងកីឡារដ្ឋបាលស្រុកភ្នំក្រវាញ និងស្រុកបាកានចុះតាមដានលើការបង្រៀន និងរៀន សាលាគោលដៅទាំង ១៩នៅស្រុកបាកាន និងភ្នំក្រវាញដូចជា សាលាបឋមអូរហេង វាល សំរោង វាលនិទ្រា អង្រួង តាសាស់ បឹងព្រះពន្លៃ រវៀង កោះស្វាយ ផ្ទះរុង និងបាកានមាន ភូមិអូរ ព្រះអំពិល បត់ត្រាច របងរមាស ព្រៃស្វាយ វត្តជ្រៃ ព្រះម្លូរ និងព្រៃផ្តៅចំនួន ២ដងក្នុងមួយឆ្នាំ ។
  - គាំទ្រការិយាល័យអប់រំនៃរដ្ឋបាលស្រុកបាកាន និងស្រុកភ្នំក្រវាញ ចុះជួយរៀបចំសាលា(សម្អាតទីធ្លាការិយាល័យ និងបន្ទប់រៀន)ចំនួន ១០សាលា ។




- **សកម្មភាពទី២៖** ពង្រឹងសមត្ថភាពមន្រ្តីអប់រំតាមសាលាគោលដៅ
  - ផ្តល់វគ្គបណ្តុះបណ្តាលចំនួន ២លើក(១លើកនៅស្រុកបាកាន និង ១លើកនៅស្រុកភ្នំក្រវាញ)ដល់គ្រូថ្នាក់ទី១ដល់ទី៣ ចំនួន ៥៧នាក់ និងនាយក នាយិកាចំនួន ១៩នាក់មកពី១៩សាលាគោលដៅអំពីរបៀបប្រើប្រាស់សម្ភារៈឧបទេសបង្រៀន ។
  - ផ្តល់វគ្គបណ្តុះបណ្តាលដល់នាយក នាយិកា និងគ្រូចំនួន៣៨នាក់អំពីការគ្រប់គ្រងទិន្នន័យលើប្រព័ន្ធ ។
  - គាំទ្រការិយាល័យអប់រំនៃរដ្ឋបាលស្រុកបាកាន និងស្រុកភ្នំក្រវាញ បើកវគ្គបណ្តុះបណ្តាលចំនួន ២លើក (១លើកនៅស្រុកបាកាន និង ១លើកនៅស្រុកភ្នំក្រវាញ) អំពី ការសរសេរកិច្ចតែងការបង្រៀនដោយបន្សី

សៀវភៅ សិក្សាគោល ស្តង់ដារអំណាន និងសៀវភៅ សិក្សាលំអិត ដែលមានគ្រូថ្នាក់ទី១ដល់ទី៣ ចំនួន ៧៥ នាក់ មកពី ១៩សាលា ។

- ដឹកនាំធ្វើថ្នាក់ និទស្សន៍ ចំនួន ៣លើក ដែលមាននាយកនាយិកាចូលរួមចំនួន ១៩នាក់ បុគ្គលិកការិយាល័យអប់រំយុវជន និងកីឡារដ្ឋបាលស្រុកបាកាន និងស្រុកភ្នំក្រវាញចំនួន ១២នាក់ នៅសាលាបឋមសិក្សាបឹងព្រះពន្លៃ បឋមសិក្សាព្រៃផ្តៅ និងបឋមសិក្សាព្រះអំពិល ។





- **កម្មភាពទី៣៖** គាំទ្រការប្រជុំ រវាង ក្រុមបច្ចេកទេស ការិយាល័យអប់រំយុជន និងកីឡានៃរដ្ឋបាលស្រុក នាយកសាលា និងប្រធានក្រុមបច្ចេកទេសថ្នាក់រៀន ដើម្បីពិនិត្យលើការបន្សុីសៀវភៅ កម្មវិធីសិក្សាលម្អិត សៀវភៅសិក្សាគោល និង សៀវភៅស្តង់ដារអំណាន(ថ្នាក់ទី១-៣)ចំនួន១៩សាលាគោលដៅ ។
  - ដឹកនាំប្រជុំក្រុមបច្ចេកទេស ជាមួយប្រធានក្រុមបច្ចេកទេសកំរិតស្រុក ចំនួន ៤លើក មកពីសាលាចំនួន ១៩ អ្នកចូលរួមសរុប ៦៧នាក់ (ស្រុកបាកាន និង ស្រុកភ្នំក្រវាញ) ។
  - ដឹកនាំប្រជុំប្រចាំជាមួយការមន្ទីរអប់រំយុជន និងកីឡាខេត្ត និង ការិយាល័យអប់រំយុជន និងកីឡានៃរដ្ឋបាលស្រុក ដើម្បីបន្សុី ផែនការ ប្រចាំខែ ។



- **សកម្មភាពទី៤៖** គាំទ្រការរៀបចំរចនាសម្ព័ន្ធ និងបណ្តុះបណ្តាល ក្រុមប្រឹក្សាកុមារនៅសាលាគោលដៅទាំង១៩
  - គាំទ្រសាលាគោលដៅទាំង១៩សាលា ធ្វើការជ្រើសរើស និងរៀបចំរចនាសម្ព័ន្ធក្រុមប្រឹក្សាកុមារ តាមសាលានីមួយៗ តាមការណែនាំរបស់ក្រសួងអប់រំ យុវជន និងកីឡា ។
  - គាំទ្រគ្រូទទួលបន្ទុកក្រុមប្រឹក្សាកុមារ នៃសាលាគោលដៅទាំង ១៩ ក្នុងការដឹកនាំបណ្តុះបណ្តាលក្រុមប្រឹក្សាកុមារចំនួន ១លើក (នៅតាមសាលានីមួយៗ) អំពីតួនាទី និងទំនួលខុសត្រូវរបស់ក្រុមប្រឹក្សាកុមារ
  - គាំទ្រ និងរៀបចំទិវាអំណានជាតិ ១១មិនា នៅសាលាបឋមសិក្សាព្រៃផ្តៅ ស្រុកបាកាន និង បឹងព្រះពន្លៃស្រុកតាលោសែនជ័យ ។

- ផ្តល់វគ្គបណ្តុះបណ្តាលក្រុមប្រឹក្សាកុមារចំនួន ១វគ្គ ដឹកនាំដោយមន្ត្រីការិយាល័យអប់រំ យុវជន និងកីឡានៃរដ្ឋបាលស្រុកភ្នំក្រវាញ ដែលមានកុមារចូលរួមចំនួន ១០នាក់ មកពី១០សាលា ។
- ផ្តល់ឯកសណ្ឋានដល់ក្រុមប្រឹក្សាកុមារចំនួន ១៩សាលាបឋមសិក្សា (២០៩នាក់) ។
- ផ្តល់សម្ភារៈសង្គ្រោះបន្ទាន់ដល់ក្រុមប្រឹក្សាកុមារចំនួន ១៩សាលាបឋមសិក្សាគោលដៅ ដូចជា ទឹកលាងរបួស បង់រុំដំបៅ ព្រេងខ្យល់ .ល. ។




- **សកម្មភាពទី៥៖** គាំទ្រនាយកសាលា និងគ្រូបង្រៀន ដើម្បីជ្រើសរើស និងបណ្តុះបណ្តាល មិត្តអប់រំមិត្ត នៅ ១៩ សាលាគោលដៅ (ការបណ្តុះបណ្តាលផ្តោតទៅលើ តួនាទី និងទំនួលខុសត្រូវ ការធ្វើផែនការ ការសម្របសម្រួល កិច្ចតែងការបង្រៀន និងការរៀបចំថ្នាក់រៀន) ។
  - ផ្តល់សម្ភារៈ សិក្សាដូចជា សៀវភៅសរសេរ ប៊ិច បន្ទាត់ ខ្មៅដៃ និងប៊ិច ដល់ មិត្តអប់រំមិត្ត ចំនួន ១៩សាលា (សៀវភៅសរសេរ ៥០ក្បាល ប៊ិច៥០ដើម បន្ទាត់៥០ដើម និងខ្មៅដៃ៥០ដើមក្នុង១សាលា)
- **សកម្មភាពទី៦៖** នៅកំឡុងពេលវិសមកាល សម្របសម្រួលគ្រូបង្រៀន អោយធ្វើការជាមួយក្រុមមិត្តអប់រំមិត្ត ដើម្បីអោយបង្រៀន សិស្សរៀនយឺត ។
  - គាំទ្រ ការិយាល័យអប់រំយុវជន និងកីឡារដ្ឋបាលស្រុកបាកាន និងស្រុកភ្នំក្រវាញ និងគ្រូសាលាគោលដៅ ១៩សាលា រៀបចំកម្មវិធីបង្រៀនសិស្សពីចម្ងាយកំឡុងការរាតត្បាតជម្ងឺ កូវីត ១៩ ។

- **សកម្មភាពទី៧៖** គាំទ្រការិយាល័យអប់រំយុវជន និងកីឡានៃរដ្ឋបាល ស្រុកបាកាន និងភ្នំក្រវាញ ដើម្បីបង្រៀនអំពីរបៀបធ្វើតេស្តបុរេគណិត និងភាសាខ្មែរទៅគ្រូសាលាគោលដៅទាំង១៩ ។
  - ផ្តល់វគ្គបណ្តុះបណ្តាល២លើក (១វគ្គនៅស្រុកបាកាន និង ១វគ្គនៅស្រុកភ្នំក្រវាញ) អំពីការបង្កើតតេស្តបុរេគណិតវិទ្យា និងបុរេភាសារខ្មែរដល់គ្រូថ្នាក់ទី ១ដល់ទី៦ ចំនួន ១៤៤នាក់ មកពី១៩សាលា ។
  - ដឹកនាំសិក្ខាសាលាឆ្លុះបញ្ចាំងលើលទ្ធផលតេស្ត ២លើក (១លើកនៅស្រុកបាកាន និង ១លើកនៅស្រុកភ្នំក្រវាញ) ។

- **សកម្មភាពទី៨៖** គាំទ្រមន្ទីរអប់រំយុវជន និងកីឡាខេត្ត និងការិយាល័យអប់រំយុវជន និងកីឡាស្រុកនៃរដ្ឋបាលស្រុកបាកាន និងស្រុកភ្នំក្រវាញ និងនាយកសាលា និងគ្រូបង្រៀន ធ្វើតេស្តបុរេគណិត និងភាសាខ្មែរ លើសិស្សសាលាគោលដៅទាំង១៩ ។
  - គាំទ្រសាលារៀនគោលដៅទាំង ១៩ធ្វើតេស្តបុរេគណិត និងភាសាខ្មែរសិស្សថ្នាក់ទី១ដល់ទី៦ចំនួន១លើក ។

- **សកម្មភាពទី៩៖** ផ្តល់សម្ភារៈ និងបង្កើតថ្នាក់គម្រូដល់សាលាគោលដៅ

- ផ្តល់សម្ភារៈ ក្នុងការរៀបចំទីចាត់ការសាលារៀន (ក្តាខៀន ១ កម្រាលកៅស៊ូ ២ដុំ និងសម្ភារៈតុបតែងមួយចំនួន)ដល់សាលាបឋមសិក្សា ព្រះម្លូរ ។
- ផ្តល់សៀវភៅរឿងនិទានកុមារដល់សាលាចំនួន ១៩សាលាគោលដៅ (៥០ក្បាលក្នុង១សាលា)
- ផ្តល់សម្ភារៈ ក្នុងការបង្កើតថ្នាក់គម្រូ (ទូកញ្ចក់ ៥ ក្តាខៀន ២ កម្រាលកៅស៊ូ ២ដុំ និងសម្ភារៈបង្រៀនមួយចំនួន) ដល់សាលាបឋមសិក្សាព្រះម្លូរ ។
- ផ្តល់សម្ភារៈអនាម័យដូចជា ម៉ាស់ និងជែលលាងដៃដល់សាលាបឋមគោលដៅចំនួន ១៩ (មួយសាលាផ្តល់ម៉ាស់ ២ប្រអប់ និងជែល ១ដប) ។
- គាំទ្រការិយាល័យអប់រំយុវជន និងកីឡារដ្ឋបាលស្រុកបាកាន និងស្រុកភ្នំក្រវាញក្នុងការដឹកនាំបង្កើតសម្ភារៈឧបទេសរៀន និងបង្រៀន ចំនួន ១១សាលា (៦សាលានៅស្រុកភ្នំក្រវាញ និង ៥នៅស្រុកបាកាន)





- **សកម្មភាពទី១០៖** សម្របសម្រួលការពិភាក្សារវាងគណៈកម្មការទ្រទ្រង់សាលា និង ការិយាល័យអប់រំយុវជន និងកីឡានៃរដ្ឋបាលស្រុកបាកាន និងស្រុកភ្នំក្រវាញ ។
  - គាំទ្រការិយាល័យអប់រំនៃរដ្ឋបាលស្រុកបាកាន និងស្រុកភ្នំក្រវាញ ដឹកនាំការប្រជុំតាមសាលាបឋមសិស្សាចំនួន ១៩ គោលដៅ ជាមួយ អាជ្ញាធរពាក់ព័ន្ធ(ក្រុមប្រឹក្សាឃុំ ប្រធានភូមិ គណៈកម្មាធិការទ្រទ្រង់សាលា និងអាណាព្យាបាលសិស្ស) លើដំណើរការអភិវឌ្ឍន៍សាលារៀន ។
  - ដឹកនាំជ្រើសរើស និងចងក្រងគណៈកម្មាធិការទ្រទ្រង់សាលានៅសាលាបឋមសក្សាគោលដៅទាំង ១៩
  - ផ្តល់វគ្គបណ្តុះបណ្តាល២វគ្គ (១វគ្គនៅស្រុកបាកាន និង ១វគ្គនៅស្រុកភ្នំក្រវាញ) ដល់ប្រធានគណៈកម្មាធិការទ្រទ្រង់សាលាចំនួន១៩នាក់ មកពី១៩សាលាបឋមសិក្សាគោលដៅអំពីតួនាទី និងទំនួលខុសត្រូវ

- **សកម្មភាពទី១១៖** គាំទ្រកុមារចូលរួមប្រជុំផែនការវិនិយោគឃុំដើម្បីផ្សារភ្ជាប់មាតាបិតា តំណាងក្លឹបយុវជន និងសហគមន៍មូលដ្ឋាន ក្នុងការធ្វើផែនការការសម្រេចចិត្ត និងសកម្មភាពផលជះលើការអភិវឌ្ឍសាលារៀន និងការអនុវត្តសាលាកុមាមេត្រី ។
  - ដឹកនាំតំណាងក្លឹបកុមារ/យុវជនចំនួន ១២នាក់ចូលរួមសមាហរណកម្ម ផែនការវិនិយោគឃុំ បីឆ្នាំរំកិល នៅស្រុកតាលោសែនជ័យ និងស្រុកបាកាន ។
  - គាំទ្រថវិកា ៨០០,០០០រៀល ក្នុង ១ក្លឹប ដល់ក្លឹបកុមារ/យុវជន ១៩ក្លឹបក្នុងការជួយកុមារងាយរងគ្រោះ និងចាស់ជរា នៅឃុំ បឹងខ្នារ បឹងបត់កណ្តោល ផ្ទះរុង និង ឃុំសំរោង ។
  - សម្រមសម្រួលតំណាងក្លឹបកុមារចំនួន ៤ឃុំពិភាក្សា និងពិគ្រោះយោបល់ជាមួយក្រុមប្រឹក្សាឃុំ លើលទ្ធផលស្រាវជ្រាវស្ថានភាពសិទ្ធិកុមារ ចំនួន១លើក ក្នុង១ឃុំ ។

▪ ផ្តល់វគ្គបណ្តុះបណ្តាលចំនួន ២វគ្គ (១វគ្គនៅស្រុកបាកាន និង ១វគ្គនៅស្រុកភ្នំក្រវាញ) ដល់ក្លឹបកុមារ/យុវជន ចំនួន ៥៧នាក់ មកពី១៩ក្លឹប ។







○ **សកម្មភាពទី១២៖** រៀបចំសិក្ខាសាលាឆ្លុះបញ្ចាំងការអនុវត្តគម្រោង និងផែនការបន្តបន្ទាប់ពីគម្រោងចប់នៅចុងឆ្នាំ ២០២០ ។

▪ រៀបចំសិក្ខាផ្សព្វផ្សាយរបាយការណ៍សិក្សាស្រាវជ្រាវពីស្ថានភាពសិទ្ធិកុមារ ប្រចាំខេត្តពោធិ៍សាត់ដែលមានអ្នកចូលរួម ១៨០នាក់/កុមារ ៥៧នាក់ ។

○ **សកម្មភាពទី១៣៖** ផ្តល់វគ្គបណ្តុះបណ្តាល ប្រធានក្លឹបយុវជន មកពី១៩ក្លិប

▪ គាំទ្រគណៈកម្មាធិការទទួលបន្ទុកកិច្ចការនារី និងកុមារ (គកនកអចិន្ត្រៃយ៍ មណ្ឌលសុខភាព) ចំនួនបួនឃុំ (បឹងខ្នារ បឹងបត់កណ្តោល ផ្ទះរុង និង សំរោង) ចុះបង្រៀនសមាជិកក្លឹបកុមារ/យុវជន ចំនួន ១៩ ក្លឹប អំពីអនាម័យខ្លួនប្រាណ និងការកាពារពីជម្ងឺកូវីត ១៩ ។

▪ ផ្តល់វគ្គបណ្តុះបណ្តាលចំនួន ២វគ្គ (១វគ្គនៅស្រុកបាកាន និង ១វគ្គនៅស្រុកភ្នំក្រវាញ) ដល់ប្រធាន និងអនុប្រធានក្លឹបកុមារ/យុវជន ចំនួន៧៦នាក់ មកពី១៩ក្លឹប អំពីការដឹកនាំប្រជុំប្រកបដោយប្រសិទ្ធិភាព ។

▪ ផ្តល់វគ្គបណ្តុះបណ្តាលចំនួន ២វគ្គ (១វគ្គនៅស្រុកបាកាន និង ១វគ្គនៅស្រុកភ្នំក្រវាញ) ដល់ប្រធាន និងអនុប្រធានក្លឹបកុមារ/យុវជន ចំនួន ៦៧នាក់ មកពី១៩ក្លឹប អំពីដំណើរការប្រមូលធាតុចូលក្នុងការកសាងផែនការអភិវឌ្ឍន៍ឃុំ ។

○ **សកម្មភាពទី១៤៖** ផ្តល់សម្ភារៈដល់ក្លឹបយុវជន ចំនួន១៩ក្លឹប ដូចជា សៀវភៅរឿងនិទាន សម្ភារកីឡា និងសម្ភារៈបង្រៀនផ្សេងៗ ។

▪ ផ្តល់សម្ភារៈកីឡា (បាល់ទះ បាល់បាល់ទាត់) និងសៀវភៅរឿងនិទានកុមារ (១០០ក្បាល១ក្លឹប) ដល់ក្លឹបកុមារចំនួន ១៩ក្លឹប ។

○ **សកម្មភាពទី១៥៖** គាំទ្រការប្រជុំប្រចាំត្រីមាសតំណាងក្លឹបយុវជន ចំនួន១៩ក្លឹប

▪ គាំទ្រការប្រជុំប្រចាំត្រីមាសរបស់គណម្មាធិការទទួលបន្ទុកកិច្ចការនារី និងកុមារ ចំនួន ៤ ឃុំ (បឹងខ្នារ និងបឹងបត់កណ្តោលស្រុកបាកាន និងឃុំ ផ្ទះរុងស្រុកតាលោសែនជ័យ និងឃុំសំរោងស្រុកភ្នំក្រវាញ) ។

▪ ដឹកនាំការប្រជុំប្រចាំត្រីមាសរបស់ក្លឹបកុមារ/យុវជន ឃុំ បឹងខ្នារ បឹងព្រះពន្លៃ ផ្ទះរុង និងសំរោង ចំនួន ៤ត្រីមាស ។





- ○ **សកម្មភាពទី១៦៖** គាំទ្រការប្រជុំប្រចាំខែ ត្រីមាស និងឆ្នាំរបស់ក្លឹបយុវជនចំនួន១៩ក្លឹប
  - គាំទ្រការប្រជុំប្រចាំខែក្លឹបកុមារ/យុវជន ចំនួន ១៩ក្លឹប ។






- ○ **សកម្មភាពទី១៧៖** សហការជាមួយគណៈកម្មាធិការទទួលបន្ទុកកិច្ចការនារី និងកុមារដើម្បីគាំទ្រក្លឹបកុមារ/យុវជន ធ្វើការសិក្សាស្រាវជ្រាវលើបញ្ហាកុមារនៅឃុំគោលដៅទាំង៤ ។
  - គាំទ្រក្លឹបកុមារ/យុវជនស្រុកបាកាន និងស្រុកភ្នំក្រវាញ ដឹកនាំស្រាវជ្រាវលើស្ថានភាពសិទ្ធកុមារ (ស្រុកបាកាន នៅភូមិអូរ ឃុំបឹងបត់កណ្តោល និងភូមិវត្តជ្រៃ ឃុំបឹងខ្នារ និងស្រុកភ្នំក្រវាញ ភូមិផ្ទះរុង ឃុំផ្ទះរុង និងភូមិព្រែក ១ ឃុំសំរោង)ដែលមានកុមារចូលរួមចំនួន ២៥០នាក់។

## ៣. បញ្ហាប្រឈមនៅក្នុងការអនុវត្តគម្រោង៖

- ការផ្លាស់ប្តូរគ្រូបង្រៀនញឹកញាប់ពេកពីសាលាមួយទៅសាលាមួយ ។
- លោកគ្រូអ្នកគ្រូ មួយចំនួន មិនបានយកវិធីសាស្រ្ត បង្រៀនដែលបានទទួលពីវគ្គបំប៉នទៅអនុវត្តក្នុងពេលបង្រៀន ។
- ការបង្រៀនពីចម្ងាយពិបាកក្នុងការតាមដានការរីកចម្រើនចំណេះដឹងរបស់សិស្ស ។
- សាលាមិនទាន់មានប្រព័ន្ធក្នុងការវាយតម្លៃការរៀន និងការបង្រៀនច្បាស់លាស់ ។
- មិនទាន់មានចំណេះដឹងច្បាស់លាស់លើការគ្រប់គ្រងទិន្នន័យសិស្ស គ្រូ និងកម្មវិធីសាលារៀន ។
- បញ្ហា COVID-19 រយៈពេលពេញ១ឆ្នាំ សាលាបានបិត ការសិក្សារបស់សិស្ស បានធ្លាក់ចុះ ទោះបីមានការជួយ បង្រៀនតាម អនឡាញ និង តាមបណ្តុំខ្នងផ្ទះ ក្តី កគុណភាពសិស្ស បានធ្លាក់ចុះ ខុសពីកំឡុងពេលមិនទាន់មាន COVID-19 ។
- ឆ្នាំ ២០២០ ជាឆ្នាំវាយតម្លៃបញ្ចប់នៃ គម្រោងអប់រំមូលដ្ឋាន នៃអង្គការ BSDA ខេត្តពោធិសាត់ ប៉ុន្តែអន្តរាគមន៍ នៃគម្រោងបានថយចុះ និង កាត់បន្ថយសកម្មភាពជាច្រើន ជាហេតុ ការគិតទុកមុនថា គុណភាពសិស្ស លើបំនិនភាសាខ្មែរ និង គណិតវិទ្យា ថយចុះ មិនអាចឆ្លើយតបនិង សុច្ចនាករនៃគម្រោង ជាមួយម្ចាស់ជំនួយ ៕

## ៤. ដំណោះស្រាយ៖

- សហការជាមួយការិយាល័យអប់រំយុជន និងកីឡា នៃរដ្ឋបាលស្រុក បណ្តុះបណ្តាលបន្ថែមទៀត
- សហការជាមួយមន្ត្រី អយក ខេត្ត ស្រុក នាយក ចុះតាមដាន ពង្រឹងលើការបង្រៀនរបស់គ្រូ លើវិធីសាស្រ្តបង្រៀន នៅតាមសាលា អោយបានទៀងទាត់ ។
- ធ្វើតេស្តជាប្រចាំជាមួយសិស្សដែលបានរៀនពីចម្ងាយ
  - សហការជាមួយមន្ត្រី អយក ខេត្ត ស្រុក ដឹននាំធ្វើថ្នាក់និទស្សន៍
- បណ្តុះបណ្តាលលើការគ្រប់គ្រងទិន្នន័យ
- សហការជាមួយការិយាល័យអប់រំយុជន និងកីឡា ចុះតាមសាលា គោលដៅ បង្កើតកម្មវិធី បង្រៀន សិស្សតាម អនឡាញ តាម អ៊ីស្តូល ដល់លោកគ្រូអ្នកគ្រូ ។
- សហការជាមួយនាយក/នាយិកា លោកគ្រូ/អ្នកគ្រូ រៀបចំបង្កើតសម្ភារៈបង្រៀន ចុះទៅបង្រៀន តាមបណ្តុំខ្ទងផ្ទះ និងទីកន្លែង អាន សិក្សា នៅតាមផ្ទះ សហគមន៍បន្ថែមតាមលទ្ធភាពដែលអាចធ្វើទៅបាន ។
- សហការជាមួយមន្ត្រី អយក ខេត្ត ស្រុក នាយក ចុះតាមដាន ពង្រឹងលើការបង្រៀនរបស់គ្រូ លើវិធីសាស្រ្តបង្រៀន នៅតាមសាលា អោយបានទៀងទាត់ ។
- សហការជាមួយនាយក/នាយិកា លោកគ្រូ អ្នកគ្រូ ចុះធ្វើតេស្តសិស្ស តាមបន្ទុំ ខ្ទងផ្ទះ ។

## ៥. សំណូមពរ៖

- សុំអោយអាជ្ញាធរដែនដីមាតាបិតា និងដៃគូរពាក់ព័ន្ធយកចិត្តទុកដាក់ពីបញ្ហាកុមារនិងស្វែងរកដំណោះស្រាយរួមគ្នា ។
- សុំឱ្យមន្ត្រីរបស់មន្ទីរ និងការិយាល័យ អប់រំ យុវជននិងកីឡានៃរដ្ឋបាលស្រុក ចុះតាមដាននិងត្រួតពិនិត្យ ឱ្យបានទៀតទាត់ ដល់នាយក នាយិកាសាលា និងលោកគ្រូ អ្នកគ្រូ ដើម្បីគុណភាពរៀន និងបង្រៀនតាមថ្នាក់នីមួយៗ ។
- សូមអោយក្រុមប្រឹក្សាឃុំដាក់បញ្ចូលរាល់បញ្ហានិងតម្រូវការរបស់កុមារចូលក្នុងកម្មវិធីវិនិយោគឃុំ
- សុំអោយអាជ្ញាធរដែនដីមាតាបិតានិងដៃគូរពាក់ពន្ឋ័យកចិត្តទុកដាក់ពីបញ្ហាកុមារនិងស្វែងរកដំណោះស្រាយរួមគ្នា ។
- សូមន្ត្រីរបស់មន្ទីរ និងការិយាល័យ អប់រំ យុវជននិងកីឡានៃរដ្ឋបាលស្រុកបង្កើតប្រព័ន្ធវាយតម្លៃ គ្រូ នាយកសាលារៀនយ៉ាងតិចមួយឆ្នាំម្តងអោយបានច្បាស់លាស់ និងសុក្រិត ។

## ១.៤. គម្រោង ការអប់រំជាមូលដ្ឋាន (BASIC EDUCATION PROJECT)៖

| | |
|---|---|
| **ក. គោលបំណង** | ៖ ពង្រឹងការអប់រំមូលដ្ឋាននូវកំរិតថ្នាក់បឋមសិក្សា |
| **ខ. ចំនួនបុគ្គលិកសរុប** | ៖ ២ នាក់ ស្រី ១ នាក់ |
| **គ. ទីតាំងគម្រោង** | ៖ ខេត្តកំពង់ឆ្នាំង ខេត្តពោធិ៍សាត់ និងខេត្តកោះកុង |
| **ឃ. ម្ចាស់ជំនួយ** | ៖ ណរ៉ាត តាមរយៈ អង្គការ សង្គ្រោះកុមារ (NORAD THROUG SCI) |
| **ង. សរុបថវិកាគម្រោង** | ៖ ៦៨,៤៥៦ ដុល្លារអាមេរិក |
| **ច. កាលបរិច្ឆេទគម្រោង** | ៖ ១ឆ្នាំ (ថ្ងៃទី១ ខែមករា ដល់ ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២០) |

## ១. សកម្មភាពអនុវត្តរបស់គម្រោងនៅក្នុងឆ្នាំ២០២០៖

### ១.១. អ្នកទទួលផលសរុប៖

គម្រោងនេះមានអ្នកទទួលផលសរុប៖ កុមារមានចំនួន ៦,៩០០ ក្នុងនោះស្រី ៣,២៩០ នាក់ និងក្មេងជំទង់ ២៧១ នាក់ ក្នុងនោះស្រីចំនួន ១៥៥ នាក់នៅសាលាគោលដៅចំនួន ២១ ។ តំបន់គោលដៅមាន៖ ពោធិ៍សាត់ (បាកាន ភ្នំក្រវាញ និងវាលវែង) កំពង់ឆ្នាំង (បរិបូរណ៍) និងខេត្តកោះកុង (បទុមសាគរ ខេមរភូមិន្ទ កោះកុង ថ្មបាំង គីរីសាគរ និងស្រែអំបិល) ។

## ២. លទ្ធផលសម្រេចបាន៖

- **សកម្មភាពទី១៖** មន្ទីរអប់រំ និងអង្គការដៃគូរបានរៀបចំឯកសារតេស្តមុនគម្រោង (Baseline Test) និងធ្វើការតេស្តស្តង់ដារប្រចាំខែ នៅសាលាបឋមសិក្សាគោលដៅចំនួន ១៣ ស្មើ ៦០% នៃខេត្តទាំងបីរបស់គម្រោង (កោះកុង ពោធិ៍សាត់ និងកំពង់ឆ្នាំង ។
- **សកម្មភាពទី២៖** ប្រជុំឆ្លើយតបលើលទ្ធផលតេស្តប្រចាំខែ ថ្នាក់ភាសាខ្មែរ និងគណិតវិទ្យាគ្រប់ថ្នាក់ទាំងអស់ ដោយមានការចូលរួមគាំទ្រដោយ មន្ត្រីការិយាល័យ មន្ទីរអប់រំ នៅសាលាគោលដៅគម្រោងទាំងអស់។
- **សកម្មភាពទី៣៖** ជួយផ្តល់បច្ចេកទេស បង្ហាត់បង្រៀនបន្ថែមដល់គ្រូបង្រៀនអំពី ការរៀន និងបង្រៀន ហើយបានបង្កើតក្រុមការការងារបច្ចេកដើម្បីជួយដល់សាលាបឋមសិក្សាគោលដៅចំនួន ៨។
- **សកម្មភាពទី៤៖** សហគមន៍ និងសាលាគោលដៅបានអង្គុយធ្វើការជាមួយគ្នាដើម្បីស្វែងរកយុទ្ធសាស្ត្រថ្មីៗដើម្បីអភិវឌ្ឍន៍សាលាអោយមាននិរន្តរភាព។
  - សាលាបឋមសិក្សាចំនួន២១ ក្នុងតំបន់គោលដៅត្រូវបានដាក់ជាសាលាអភិវឌ្ឍន៍។
- **សកម្មភាពទី៥៖** សាលាបឋមសិក្សាចំនួន ១៨ បានរៀបចំចងក្រងគណៈកម្មាធិការគ្រប់គ្រងថវិកាសាលា (កោះកុង ១០ និងខេត្តពោធិ៍សាត់ ៨ បឋមសិក្សា)។
  - គណៈកម្មារធិការខាងលើមានតួរនាទីយ៉ាងសំខាន់សម្រាប់គៀងគរថវិកា និងធនធាននៅក្នុងសហគមន៍ដើម្បីជួយសាលា (ថវិកា កម្លាំងពលកម្ម និងការចូលរួមផ្សេងៗ ទៀត)។
- **សកម្មភាពទី៦៖** ចូលរួមពង្រឹងវប្បធម៌ នៃការអានសៀវភៅ និងសកម្មភាពដឹកនាំសិស្សធ្វើសកម្មភាពសា លាផ្សេងៗ ។
  - សាលាបឋមសិក្សាចំនួន២ បានរៀបចំកម្មវិធីទិវាថ្នាក់អំនានអន្តរជាតិ (អូតាប៉ោង និងបឋមសិក្សាត្រពាំងចាន់) ។ ជាក់ស្តែងសិស្ស ១៦ នាក់ (០៩ នាក់ស្រី) បានរៀបចំវេទិកាថ្នាក់អំណានអន្តរជាតិ ដូចជាអ្នកដឹកនាំកម្មវិធីប្រជុំ គណៈកម្មាធិការ និងជំនួយការដឹកនាំកម្មវិធីជាដើម។

- **សកម្មភាពទី៧៖** អំឡុងពេលកូវីដ១៩ បានរីករាលដាល គម្រោងបានសហការជាមួយការិយាល័យអប់រំបង្កើត



ក្រុមបន្ទាន់ដើម្បីរាយការណ៍អំពីគម្រោង (កោះកុង និងខេត្តពោធិ៍សាត់) និង ២ស្រុក (១ខេត្ត កោះកុង និង ១ ខេត្តពោធិ៍សាត់) សាលាចំនួន ៣ (១ កំពង់ឆ្នាំង និង ៣ ខេត្តពោធិ៍សាត់)។
- **សកម្មភាពទី៨៖** គម្រោងបានសហការជាមួយការិយាល័យអប់រំដើម្បីធ្វើផែនការឯកសារ តេស្ត។
  - បឋមសិក្សាកោះវត្ត (មានធាតុបួនសំខាន់គឺ ការតេស្តប្រចាំខែ ពេលវេលាសម្រាប់រៀបចំផែនការតេស្ត របៀបនៃការការអនុវត្ត និងរបៀបបង្ហាញលទ្ធផលតេស្ត)
- **សកម្មភាពទី៩៖** សាលាគោលដៅចំនួន ១០ បានរៀបចំកម្មវិធីវាយតម្លៃខ្លួនឯងលើ (QLF) ពីដងក្នុង ១ឆ្នាំ។
  - ៥០% នៃក្រុមប្រឹក្សាកុមារ គឺសកម្មចូលរួមពាក់ព័ន្ធ និងកម្មវិធីអភិវឌ្ឍន៍សាលា។
- **សកម្មភាពទី១០៖** ផ្តល់វគ្គបណ្តុះបណ្តាលបន្ថែមដល់គ្រូបង្រៀន និងក្រុមប្រឹក្សាកុមារនៅសាលាគោលដៅ។
  - បឋមសិក្សាចំនួន ៣ (ព្រងិល លាច និងកោះចម្លង។
- **សកម្មភាពទី១១៖** ជួយពង្រឹងសាលាបឋមសិក្សាចំនួន ១០ ដើម្បីរៀបចំផែនការនិរន្តភាព និង សាលាចំនួន៦ បាននឹងកំពុងអនុវត្តន៍។
- **សកម្មភាពទី១២៖** ជួយរៀបចំសម្ភារៈសិក្សាសម្រាប់សិស្សរៀនយឺត រៀន និងបង្រៀន។
  - សាលាគោលដៅចំនួន ៤ នៅក្នុងស្រុកបាកាន ខេត្តពោធិ៍សាត់ បានរៀបចំកម្មវិធីឆ្លុះបញ្ចាំងប្រចាំត្រីមាសអំពីផែនការគ្រូបង្រៀនប្រកបដោយវិជ្ជាជីវៈ។
- **សកម្មភាពទី១៣៖** មន្ទីរ និងការិយាល័យអប់រំ បានរៀបចំបច្ចេកទេស និងសម្របសម្រួលឯកសារតេស្ត។
  - សាលាចំនួន ៧ បានរៀបចំកម្មវិធីតេស្តប្រចាំខែ ប្រចាំត្រីមាស តេស្តមុនវគ្គ និងតេស្តក្រោយវគ្គ (អូតាប៉ោង តាលូ កោះវត្ត លាច ព្រងិល កោះចម្លង និងស្ទឹងថ្មី)
- **សកម្មភាពទី១៤៖** សាលាគោលដៅចំនួន ៧ បានគាំទ្រថវិកាពីអង្គការសង្គ្រោះកុមារ ដើម្បីចូលរួមប្រយុទ្ធប្រឆាំងកូវីដ ១៩ (ស្រុកក្រវាញ ៣ និងបាកានចំនួន៤)។

○ **សកម្មភាពទី១៥៖** រៀបចំផែនការ និងការបង្រៀនពីចម្ងាយនៅសាលាបឋមសិក្សាគោលដៅ (កោះស្រឡៅ តានួន និងដងពែង) ដើម្បីជួយពួកគេបន្ថែមពីការរៀនតាមប្រព័ន្ធអ៊ីនធើណេត ក្រុមហ្វេសបុក។



○ **សកម្មភាពទី១៦៖** សាលាគោលដៅចំនួន ១០ បានធ្វើការវាយតម្លៃខ្លួនឯង (QLF) ពីដងក្នុង១ឆ្នាំ ។
  ▪ សាលាបឋមសិក្សា ខ្នាទទឹង កោះវត្ត តាលូ អូតាប៉ោង ប្រងិល លាច កោះចម្លង ដូននាគ ស្ទឹងថ្មី និង អន្លង់រាជ ។

○ **សកម្មភាពទី១៧៖** សាលាចំនួន៥ បានរៀបចំឯកសារថ្មីៗ សម្រាប់វាយតម្លៃសិស្សរៀនខ្សោយ នៅក្នុងការរៀន និងបង្រៀន។
  ▪ បឋមសិក្សាអូតាប៉ោង តាលូ លាច កោះស្តេច និងស្ទឹងថ្មី ។

○ **សកម្មភាពទី១៨៖** សាលាចំនួន៥បានរៀបចំប្រជុំឆ្លុះបញ្ចាំងផែនការឧបករណ៍រៀងរាល់ត្រីមាស។
  ▪ ស្រុកបាកាន ៣ វាលវែង និងក្រវាញ ។

○ **សកម្មភាពទី១៩៖** មន្ទីរ ការិយាល័យអប់រំ បានគាំទេបច្ចេកទេ និងសម្របសម្រួលការរៀបចំឯកសារតេស្ត។
  ▪ បឋមសិក្សាអូតាប៉ោង តាលូ លាច និងកោះវត្ត ។

○ **សកម្មភាពទី២០៖** សាលាបឋមសិក្សាចំនួន ៧ បានអនុវត្តសកម្មភាពតេស្តមុនវគ្គ និងក្រោយវគ្គប្រចាំខែ និងប្រចាំត្រីមាស។
  ▪ បឋមសិក្សាអូតាប៉ោង តាលូ កោះវត្ត លាច ព្រងិលកោះចម្លង និងស្ទឹងថ្មី ។

○ **សកម្មភាពទី២១៖** ចុះពង្រឹងសាលាមុនបញ្ចប់គម្រោង បានចំនួន ៥ សាលាគោលដៅ
  ▪ ស្រុកបាកាន៣ ក្រវាញ និងវាលវែង ។

○ **សកម្មភាពទី២២៖** សាលាចំនួន ២ បានចុះគាំទ្រប្រជុំបច្ចេកទេសប្រចាំថ្ងៃពុធ (សាលាបង្ហាញ)
  ▪ បឋមសិក្សា តាលូ និងកោះវត្ត ។

○ **សកម្មភាពទី២៣៖** សាលាចំនួន១០ បានទទួលថវិកាគាំទ្រពីអង្គការសង្គ្រោះកុមារសម្រាប់ផ្សព្វផ្សាយអំពីសារកូវីដ-១៩ ។
  ▪ ស្រុកក្រវាញ៣ បាកាន៤ និងវាលវែង៣ ។

○ **សកម្មភាពទី២៤៖** ផ្តល់សៀវភៅអំណានផ្សេងៗ និងល្បែងអំណានសម្រាប់ថ្នាក់ទី ១ និងទី ៣

- បានផ្តល់ចំនួន១ សាលា គឺសាលាបឋមសិក្សាស្ទឹងថ្មី សម្រាប់ទិញរឿងនិទានចម្រុះ និង សម្ភារដាក់កន្លែងអានក្នុងសហគមន៍ សរុបថវិកាបដិភាគ ចំនួន ៥០ ដុល្លា ។



- **សកម្មភាពទី២៥៖** បណ្តុះបណ្តាលគ្រូបង្រៀនស្តីពី ការបង្រៀនអក្សរ និងលេខ ថ្នាក់ទី១ ដល់ទី៣ ការរៀបចំតេស្តវាយតម្លៃការសិក្សារបស់កុមារ និងបំប៉នសិស្សរៀនយឺត នៅសាលាចំនួន១០ ក្នុងគោលដៅ ។
- **សកម្មភាពទី២៦៖** ប្រជុំបង្កើនការយល់ដឹងដល់នាយកសាលាគណៈកម្មការទ្រទ្រង់សាលា គ្រូបង្រៀន និង សិស្សានុសិស្សលើគោលការណ៍ និងស្តង់ដារគុណភាពរបស់ QLE និង បោះពុម្ពជាបដាផ្សេងៗ ។
- **សម្មភាពទី២៧៖** ផ្តល់វគ្គបំប៉នដល់នាយករង និង ក្រុមប្រឹក្សាកុមារ ដើម្បីពង្រឹង និង រំលឹកពីតួនាទីនិងភារៈកិច្ចរបស់ក្រុមប្រឹក្សាកុមារ ។
- **សកម្មភាពទី២៨៖** សាលាបឋមសិក្សាចំនួន ៤ បានទទួលឯកសារតេស្ត និងតេស្តសិស្ស
  - បឋមសិក្សាត្រកួន កោះស្រឡៅ អង្គរភ្នំខ្នុង និងកោះស្តេច
- **សកម្មភាពទី២៩៖** សាលាបឋមសិក្សាចំនួន ៣ បានពង្រឹងលើ QLE តេស្ត និងការពង្រឹងក្រុមប្រឹក្សាកុមារ
  - បឋមិសិក្សាកោះស្តេច កោះស្រឡៅ អង្គរភ្នំខ្នុង ។



- **សកម្មភាពទី៣០៖** ប្រជុំផែនការគ្រោះមហន្តរាយដល់សាលាគោលដៅ និងការិយាល័យអប់រំ
  - សាលាកោះស្រឡៅ បឹងកាឆាង កោះស្តេច និងតានួន (ការិយាល័យ កោះកុង មណ្ឌលសីមា គីរីសាគរ និង បទុមសាគរ) ។

- **សកម្មភាពទី៣១៖** ចុះជួយ និងសម្របសម្រួលផែនការអភិវឌ្ឍន៍សាលា
  - បឋមសិក្សាជីផាត បឹងការឆាង ទីរួមខេត្ត និងកោះកុង
- **សកម្មភាពទី៣២៖** សកម្មភាពចុះផ្សព្វផ្សាយសារកូវីដ ១៩ ដល់សាលាគោលដៅ
  - ស្រុកកោះកុង២ មណ្ឌលសីមា១ គីរីសាគរ១ ស្រែអំបិល៣ បទុមសាគរ១ និងថ្មបាំង១ ។



**៣. សំណូមពរ និងផែនការបន្ទាប់៖**

- សូមឱ្យសាលាបន្តការអនុវត្តទោះបីគម្រោងនេះត្រូវបានបញ្ចប់ក៏ដោយ
- ចូលរួមវាយតម្លៃគម្រោងបញ្ចប់វគ្គ
- ចែករំលែកពត៌មានអំពីស្ថិតិសាលាគោលដៅ ។

# ២. កម្មវិធីសុខភាព (HEALTH PROGRAM)៖

## ២.១. គម្រោងអាជីវកម្មខ្នាតតូច (FINANCING FUTURE PROJECT)៖

**ក. ចំនួនបុគ្គលិកសរុប** ៖ ១ នាក់ (ស្រី០នាក់)
**ខ. ទីតាំងគម្រោង** ៖ ខេត្តកំពង់ចាម
**គ. ម្ចាស់ជំនួយ** ៖ គ្លុបមេដ (GLOBMED)
**ឃ. សរុបថវិកាគម្រោង** ៖ ៤,០០០.០០ ដុល្លារអាមេរិក
**ង. កាលបរិច្ឆេទគម្រោង** ៖ ១ឆ្នាំ (ថ្ងៃទី១ ខែមករា ដល់ ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២០)

**១. គោលបំណងរបស់គម្រោង៖** ការធ្វើឱ្យប្រសើរឡើងនូវជីវភាពគ្រួសារ និងអាចមានលទ្ធភាពក្នុងការបញ្ជូនកូនឱ្យទៅសាលារៀន ។

## ២. សកម្មភាពអនុវត្តរបស់គម្រោងនៅក្នុងឆ្នាំ២០២០៖

២.១. ផ្តល់ការបណ្តុះបណ្តាល ផ្នែកអាជីវកម្មខ្នាតតូច និងផ្តល់ប្រាក់ទុន មុនពេលដែលយើងបានផ្តល់នូវប្រាក់ទុន សមាជិកម្នាក់ៗ បានទទួលវគ្គបណ្តុះបណ្តាលមុនទទួលថវិកា។ វគ្គបណ្តុះបណ្តាលនេះបានផ្តល់ចំណេះដឹងដល់អ្នកទទួលផលជាច្រើនអំពី៖ ការរៀបចំផែនការអាជីវកម្ម អនាម័យបរិស្ថាន សុខភាព និងផែនការហិរញ្ញវត្ថុ ។

២.២. ការផ្តល់ប្រាក់ផ្តល់ប្រាក់ទុនមានចំនួនត្រឹមតែ ២០០ដុល្លារ ក្នុង ១ គ្រួសារ ឬតិចជាងនេះទៅតាមស្ថានភាពជាក់ស្តែង។ ការផ្តល់ប្រាក់ទុននេះសម្រាប់តែគ្រួសារក្រីក្រមានកូនរៀន ហើយចង់បង្កើត និងបង្កើនអាជីវកម្មរបស់ពួកគេ។ ការផ្តល់ប្រាក់ទុននេះចាប់ផ្តើមតាំងពីខែមិថុនា ឆ្នាំ ២០១៦ រហូតដល់បច្ចុប្បន្ននេះយើងមានអ្នកទទួលផលសរុបចំនួន ១២០ (ស្រី ១០៦) គ្រួសារ ៕



| បញ្ហាជួបប្រទះ | ដំណោះស្រាយ |
|---|---|
| អ្នកទទួលផលមួយចំនួនពុំទាន់បានយល់ដឹងច្បាស់ពីផែនការអាជីវកម្មពេញលេញ ដូច្នេះធ្វើអោយពួកគាត់មានចំណេះដឹងមិនគ្រប់គ្រាន់ សម្រាប់ការងារមួយនេះ។ | បុគ្គលិក និងប្រធានក្រុម ចុះសហគមន៍ ដើម្បីពន្យល់ពួកគាត់បន្ថែមអំពីអ្វីដែលគាត់បានរៀនពីផែនការអាជីវកម្ម។ |

## ៣. ការចុះត្រួតពិនិត្យ និងការបង្ហាត់បង្រៀនបន្ថែម៖

គ្រួសារនិមួយៗ ត្រូវបានចុះត្រួតពិនិត្យមួយខែម្តង ឬទៅតាមស្ថានភាពជាក់ស្តែង បុគ្គលិកគម្រោងនិងអ្នកស្ម័គ្រចិត្តភូមិ បានចុះសាកសួរសុខទុក អំពីប្រាក់ចំណូល និងការចំណាយ ផែនការហិរញ្ញវត្ថុ មុខរបរ ការសិក្សារបស់កូនៗរបស់ពួកគេ ហើយក៏បានបង្រៀនបន្ថែមពីបច្ចេកទេសនៃការសរសេរចំណូលចំណាយ និងចំណេះដឹងផ្សេងៗ ពីអាជីវកម្មរបស់ពួកគេផងដែរ ។

| បញ្ហាជួបប្រទះ | ដំណោះស្រាយ |
|---|---|
| អ្នកទទួលផលមួយចំនួនពុំទាន់បានយល់ដឹងច្បាស់អំពីផែនការកត់ត្រា ចំណូល និងចំណាយច្បាស់លាស់ ។ | បុគ្គលិក និងប្រធានក្រុម ត្រូវចុះណែនាំបន្ថែមអំពីសារៈសំខាន់នៃការ ផែនការកត់ត្រា ចំណូល ចំណាយឱ្យច្បាស់លាស់ ។ |

## ៤. ការបង្កើតប្រាក់ចំណូលតាមរយៈការលក់ និងបង្វិលប្រាក់ទុន៖

អ្នកទទួលផលទាំងអស់អាចបង្វិលប្រាក់ទុនចូលក្រុមជួយខ្លួនឯងតាម ថ្ងៃ ខែ ដែលបានកំណត់ ឬទៅតាមស្ថានភាពជាក់ស្តែង។ ការលក់ដូរប្រចាំថ្ងៃអាចបង្កើនប្រាក់ចំណូលក្នុងគ្រួសារដើម្បីគាំទ្រការសិក្សាកូនៗ របស់ពួកគេ ។ ប្រាក់

ចំណូលជាមធ្យមចន្លោះពី ៣៥០,០០០ រៀល ទៅ ៤៥០,០០០រៀល។ ប្រាក់ចំណូលដែលគាត់ទទួលបានបង់ខ្លះមកក្រុមជួយខ្លួនឯង និងខ្លះទៀតសម្រាប់ផ្គត់ផ្គង់គ្រួសារនឹងជាពិសេសសម្រាប់ការសិក្សាកូនៗ របស់ពួកគេ។

| បញ្ហាជួបប្រទះ | ដំណោះស្រាយ |
|---|---|
| ការសងប្រាក់ទុនមានការយឺតយាវនៃការសងប្រាក់ទុនត្រលប់មកក្រុមវិញ។ | បុគ្គលិកបានផ្តល់យោបល់ និងអនុញ្ញាតអោយពួកគាត់បង់តាមលទ្ធភាពដែលមាន មិនចាំបាច់តាមតារាងកំណត់ឡើយតែយ៉ាងហើចបានជារៀងរាល់ខែទោះបីតិចក៏ដោយ។ |
| ជម្ងឺកូវីដធ្វើឱ្យការលក់មានភាពពិបាកនាំឱ្យការបង់ប្រាក់មានភាពយឺតយាវ។ | ការបង់ប្រាក់មកក្រុមវិញមានភាពយឺតយាវ និងត្រូវបានពន្យាពេលតាមការកំណត់។ |

### ៥. ការប្រជុំប្រចាំខែជាមួយ អ្នកសន្សំប្រាក់៖

ការប្រជុំប្រចាំខែត្រូវបានធ្វើ នៅស្រុកកំពង់សៀម និងកំពង់ចាម។ វាពិតជាមានសារៈសម្ខាន់ណាស់ចំពោះសមាជិក



ដែលពួកគេអាច ជួយគ្នាទៅវិញទៅមក ដោយសមាជិកក្រុមទាំងអស់ យកលុយមកដាក់ក្រុមហើយអនុញ្ញាត្តិអោយក្រុម ខ្ចីលុយក្នុងសមាជិកក្រុមរបស់ពួកគាត់ ចំណែកឯការកត់ត្រា និងត្រួតពិនិត្យ គឺប្រធានក្រុម និងបុគ្គលិកជាអ្នកជួយសម្របសម្រួល។ កំឡុងពេលប្រជុំ សមាជិកក្រុមបានប្រមូលប្រាក់កម្ចីមកវិញតាម កិច្ចសន្យាដែលបានចែង។

| បញ្ហាជួបប្រទះ | ដំណោះស្រាយ |
|---|---|
| សមាជិកក្រុមសន្សំប្រាក់មានចំណេះដឹងតិចតួច និងពុំទាន់យល់ដឹងច្បាស់អំពីដំណើរការសន្សំប្រាក់ជួយខ្លួនឯង ។ | បុគ្គលិក ប្រធានក្រុមបានធ្វើសមាធិប្រមូលអារម្មណ៍ និងជួយបង្ហាត់បង្រៀនបន្ថែមដល់ក្រុមសន្សំប្រាក់ទាំងអស់កំឡុងពេលប្រជុំប្រចាំខែ ។ |

## ២.២. គម្រោង ការធ្វើអោយប្រសើរឡើងនូវជីវភាពរស់នៅរបស់អ្នករស់នៅជាមួយមេរោគអេដស៍តាមរយៈការចិញ្ចឹមមាន់ (CHICKEN RAISING PROJECT)៖

**ក. ចំនួនបុគ្គលិកសរុប** ៖ ១ នាក់ (ស្រី០នាក់)
**ខ. ទីតាំងគម្រោង** ៖ ខេត្តត្បូងឃ្មុំ
**គ. ម្ចាស់ជំនួយ** ៖ គ្លូបមេដ (GLOBMED)
**ឃ. សរុបថវិកាគម្រោង** ៖.៤,០០០ ដុល្លារ
**ង. កាលបរិច្ឆេទគម្រោង** ៖ ១ឆ្នាំ (ថ្ងៃទី០១ ខែមករា ដល់ ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២០)

**១. គោលបំណងរបស់គម្រោង**៖ ជួយអ្នករស់នៅជាមួយមេរោគអេដស៍ក្នុងតំបន់គោលដៅដើម្បីលើកកម្ពស់សន្តិសុខ និងសុខភាពជីវភាពរស់នៅរបស់ពួកគេ ។

## ២. សកម្មភាពអនុវត្តរបស់គម្រោងនៅក្នុងឆ្នាំ២០២០៖

### ២.១. ផ្តល់ការបណ្តុះបណ្តាល ផ្នែកចិញ្ចឹមមាន់ និងផ្តល់ប្រាក់ទុនមុនពេល ដែលយើងបានផ្តល់នូវប្រាក់ទុន៖

សមាជិកម្នាក់ត្រូវចូលរួមការបណ្តុះបណ្តាលមួយវគ្គ។ អ្នកទទួលផលត្រូវយល់ដឹងអំពីអនាម័យបរិស្ថាន សុខភាព និងចាក់ថ្នាំបង្ការ ការបែងចែកចំណាត់ថ្នាក់មាន់ ដែលមានអាយុ និងមាឌខុសគ្នាដាក់ដោយឡែក និងពិនិត្យមើលតម្លៃនៅលើទីផ្សារតាររដូវកាលនិមួយៗ ដើម្បីអោយច្បាស់ថាអាចនាំចូលក្នុងទីផ្សារបាន ។



ការផ្តល់ប្រាក់ទុនសម្រាប់ឆ្នាំ ២០១៥ ត្រូវបានបញ្ចប់នៅក្នុងខែមិថុនារួចរាល់ហើយ។ បច្ចុប្បន្ននេះគម្រោងមាន ២ ស្រុក ក្នុងខេត្តត្បូងឃ្មុំ គឺស្រុកអូរាំងឪ និងស្រុកពញាក្រែក។ ១៨ គ្រួសារទៀតដែលស្ថិតនៅក្នុងស្រុក អូររាំងឪ និងស្រុកពញាក្រែកទទួលបានប្រាក់ទុនចំនួន ១២០$។ ជាជំហានដំបូងនៃដើមខែមិថុនាពួកគេទទួលបាន ៦០$ ដើម្បីទិញសម្ភារៈសម្រាប់ទ្រុងមាន់។ លើកទី២ ពួកគាត់ទទួលបាន ៦០ដុល្លាទៀតយកទៅទិញពូជមាន់មកចិញ្ចឹម ទិញចំណី និងថ្នាំ បង្ការ។

| បញ្ហាជួបប្រទះ | ដំណោះស្រាយ |
|---|---|
| អ្នកទទួលផលមួយចំនួន ពុំទាន់បានចូលរួមវគ្គបណ្តុះបណ្តាលពេញលេញ ដូច្នេះធ្វើអោយពួកគាត់មានចំណេះដឹងមិនគ្រប់គ្រាន់ សម្រាប់ការងារនេះ ។ | បុគ្គលិកចុះសហគមន៍ ដើម្បីពន្យល់ពួកគាត់ និងបង្ហាត់បង្រៀនបន្ថែមអំពីហានិភ័យនៃការចិញ្ចឹមមាន់ ប្រកបដោយប្រសិទ្ធភាពខ្ពស់ ។ |

### ២.២. ចុះត្រួតពិនិត្យ និងបង្រៀនការចិញ្ចឹមមាន់បន្ថែម៖

គ្រួសារនិមួយៗ ត្រូវបានចុះត្រួតពិនិត្យមួយខែម្តង ឬទៅតាមស្ថានភាពជាក់ស្តែង។ បុគ្គលិកគម្រោងបានត្រួតពិនិត្យនូវប្រាក់ចំណូល និងការចំណាយផ្នែកមុខរបរចិញ្ចឹមមាន់ ហើយក៏បានបង្រៀនបន្ថែមពីបច្ចេកទេសនៃការថែរក្សា និងការចិញ្ចឹមមាន់ ការជួសជុលថែទាំទ្រុងមាន់ និងការចុះស្រង់តម្លៃទីផ្សារ ។

| បញ្ហាជួបប្រទះ | ដំណោះស្រាយ |
|---|---|
| អ្នកទទួលផលមួយចំនួនមិនទាន់មានទំនុកចិត្តទៅលើរបៀបនៃការផ្តល់ចំណី និងថែទាំមាន់ ។ | បុគ្គលិកត្រូវផ្តល់ពីររបៀបការផ្តល់ចំណី គឺទៅតាមអាយុរបស់មាន់ អនាម័យ សំអាតទ្រុង និងដាក់ទឹកអោយមាន់ផឹកទៀងពេល ។ |

## ២.៣. ការបង្កើនប្រាក់ចំណូលតាមរយៈការលក់ និងបង្វិលប្រាក់ទុននៃការចិញ្ចឹមមាន់៖

គ្រួសារទាំងអស់អាចបង្វិលប្រាក់ទុនមកក្រុមវិញតាមថ្ងៃខែដែលបានកំណត់។ ពួកគាត់បានលក់មាន់ ពីរដងក្នុងមួយឆ្នាំ ទទួលបានប្រាក់ចំណូលប្រមាណ ពី ៤០០,០០០៛ ទៅ ៦០០,០០០៛។ បន្ទាប់ពីពួកគេបានលក់ហើយម្តង គាត់បានបង្វិលប្រាក់ទៅក្រុមវិញ ហើយខ្លះនៅបន្តការស្នើរសុំប្រាក់ទុនថ្មីម្តងទៀត ។

| បញ្ហាជួបប្រទះ | ដំណោះស្រាយ |
|---|---|
| ពេលលក់មាន់ៗ ចុះថ្លៃ | បុគ្គលិកចុះតាមសហគមន៍ និងជំរុញពួកគាត់លក់មាន់នៅរដូវកាលដែលគេត្រូវការ ដូចជារដូវកាល ថ្ងៃឈប់សម្រាក់ បុណ្យជាតិ ធំៗ របស់ខ្មែរ ឬចិន ទើបបានថ្លៃ ។ |

## ២.៤. ការប្រជុំប្រចាំខែជាមួយ អ្នកសន្សំប្រាក់៖

ការប្រជុំប្រចាំខែត្រូវបានធ្វើជា២ស្រុក គឺនៅស្រុកអូររាំងឪ និងស្រុកពញាក្រែក ។ ការប្រជុំនេះមានសារៈសំខាន់ណាស់ចំពោះសមាជិក ដែលពួកគេអាចជួយគ្នាទៅវិញទៅមក ដោយសមាជិកក្រុមទាំងអស់យកលុយ មកដាក់ក្រុមហើយអនុញ្ញាត្តិអោយក្រុម ខ្ចីលុយក្នុងសមាជិកក្រុមរបស់ពួកគាត់ ចំណែកឯការកត់ត្រា និងត្រួតពិនិត្យ គឺជាប្រធានក្រុម និងបុគ្គលិកជាអ្នកជួយសម្របសម្រួល ។ កំឡុងពេលប្រជុំសមាជិកក្រុមបានប្រមូលប្រាក់កម្ចីមកវិញតាម កិច្ចសន្យាដែលបានចែង ។



| បញ្ហាជួបប្រទះ | ដំណោះស្រាយ |
|---|---|
| ក្រុមសមាជិកប្រាក់សន្សំប្រាក់មិនមានការតាំងចិត្តនិងគោលបំណងខ្ពស់ក្នុងការចូលរួមក្នុងក្រុម | បុគ្គលិកបានធ្វើសមាធិប្រមូលអារម្មណ៍ និងណែនាំបន្ថែមពីសារៈសំខាន់ របស់ក្រុមសន្សំប្រាក់។ |

## ៣. កម្មវិធីអភិបាលកិច្ចល្អ (GOOD GOVERNANCE PROGRAM)៖

### ៣.១. គម្រោង គណនេយ្យភាពសង្គម ធ្វើឲ្យប្រសើរឡើងនូវសេវាសាធារណៈ (IMPLEMENTATION OF SOCIAL ACCOUNTABILITY FOR BETTER PUBLIC SERVICE DELIVERY PROJECT (I-SAF_PHASE I)៖

**ក. ចំនួនបុគ្គលិកសរុប** ៖ ២ នាក់ (ស្រី ០នាក់)
**ខ. ទីតាំងគម្រោង** ៖ ខេត្តកំពង់ចាម
**គ. ម្ចាស់ជំនួយ** ៖ សហភាពអ៊ឺរ៉ុប តាមរយៈ អង្គការ ទស្សនៈពិភពលោក (EU through WVI-C)
**ឃ. សរុបថវិកាគម្រោង** ៖ ៣៥,៧៧៤ ដុល្លារ
**ង. កាលបរិច្ឆេទគម្រោង** ៖ ១ឆ្នាំ (ថ្ងៃទី០១ ខែមករា ដល់ ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២០)

**១. គោលបំណងរបស់គម្រោង៖** ពង្រឹងតំរូវការនៃគណនេយ្យភាពសង្គមនៅក្នុងដំណើរការកែទម្រង់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិដើម្បីកែលម្អការផ្តល់សេវាសាធារណៈនៅកម្ពុជា ។

### ២. សកម្មភាពអនុវត្តគម្រោង៖

### ២.១. លទ្ធផលសម្រេចបានពីការអនុវត្តគម្រោង៖

- **សកម្មភាពទី១៖** ចងក្រងគណៈកម្មាធិការគ្រប់គ្រងផែនការថវិកា (JAAP-C) និងការិយាល័យស្រុក ការិយាល័យ អប់រំថ្នាក់ស្រុក និងខេត្ត ។






- **សកម្មភាពទី២៖** រៀបចំការបណ្តុះបណ្តាលកសាងសមត្ថភាព JAAP-C ទំនួលខុសត្រូវ ការត្រួតពិនិត្យ វាយតម្លៃ និងរបាយការណ៍ ។

- **សកម្មភាពទី៣៖** រៀបចំវាយតម្លៃខ្លួនឯងនៃ ៣ វិស័យ ជាមួយអ្នកផ្តល់សេវាដើម្បីផ្តល់ព័ត៌មានដល់គាត់អំពីការដាក់ពិន្ទុសម្រាប់សហគមន៍ ។

- **សកម្មភាពទី៤៖** រៀបចំការប្រជុំជាមួយអ្នកសម្របសម្រួលគណនេយ្យភាពសង្គម (CAFs) ជារួម និងបុគ្គល
- **សកម្មភាពទី៥៖** ធ្វើការយ៉ាងជិតស្និតជាមួយ រដ្ឋបាលថ្នាក់ក្រោមជាតិ (SNAs) ដើម្បីធ្វើឱ្យប្រសើរឡើងសមត្ថភាព និងគុណភាពនៃការប្រមូលទិន្នន័យ ការបញ្ចូល និងសុពលភាព។ ការជ្រើសរើសបុគ្គលិករដ្ឋបាលថ្នាក់ក្រោមជាតិដែលបានជ្រើសរើសក្នុងការបណ្តុះបណ្តាល ។
- **សកម្មភាពទី៦៖** ធ្វើការយ៉ាងជិតស្និតជាមួយ រដ្ឋបាលថ្នាក់ក្រោមជាតិ (SNAs) ដើម្បីធ្វើឱ្យប្រសើរឡើងសមត្ថភាព និងគុណភាពនៃការប្រមូលទិន្នន័យ ការបញ្ចូល និងសុពលភាព។ ការជ្រើសរើសបុគ្គលិករដ្ឋបាលថ្នាក់ក្រោមជាតិដែលបានជ្រើសរើសក្នុងការបណ្តុះបណ្តាល ។



- **សកម្មភាពទី៧៖** ភ្ជាប់ប្រជាពលរដ្ឋ ជាពិសេសក្រុមងាយរងគ្រោះដើម្បីចូលរួមប្រជុំជាមួយ CC, HCMC និង SSC ។







- **សកម្មភាពទី៨៖** អ្នកសម្របសម្រួលគណនេយ្យភាពសង្គមបានចុះសាកសួរគ្រួសារ ងាយរងគ្រោះដើម្បីពង្រឹងចំណេះដឹង និងការប្រើប្រាស់ព័ត៌មានរបស់ពួកគេ ។

- **សកម្មភាពទី៩៖** រៀបចំការវេទិការៀនការរៀនសូត្រសម្រាប់ថ្នាក់ក្រុង និងស្រុក

- **សកម្មភាពទី១០៖** រៀបចំការប្រជុំជាមួយ CAFs ដើម្បីលើកឡើងពី I4C និងការលើកកំពស់ការចូលរួមរបស់សហគមន៍ ។

- **សកម្មភាពទី១១៖** ផ្សព្វផ្សាយ I4C ចល័ត Kiosk នៅតាមសហគមន៍គោលដៅ
- **សកម្មភាពទី១២៖** រៀបចំដៃគូរប្រជុំឆ្លុះបញ្ចាំងគម្រោងនៅកម្រិតគ្រួសារលើ I4C (សិទ្ធិ ថវិកា និងការអនុវត្ត)
- **សកម្មភាពទី១៣៖** រៀបចំវគ្គបណ្តុះបណ្តាលម៉ូឌុល ១ និង២ លើការណែនាំគម្រោង I-SAF និង I4Cs (ការជ្រើសអ្នកផ្តល់សេវា)។
- **សកម្មភាពទី១៤៖** ចូលរួមក្នុងវគ្គបណ្តុះបណ្តាលការត្រួតពិនិត្យឡើងវិញ និងសុពលភាពនៃ I4Cs ដើម្បីធានាភាពត្រឹមត្រូវ ។
- **សកម្មភាពទី១៥៖** ដឹកនាំការប្រជុំចាប់ផ្តើមជាមួយអ្នកពាក់ព័ន្ធសំខាន់នៅក្នុងឃុំតំបន់គោលដៅ
- **សកម្មភាពទី១៦៖** ដាក់បញ្ចូលគ្នាកម្មវិធីវិនិយោគឃុំ (CIP) និងការដាក់សកម្មភាពបញ្ចូលគ្នា JAAP DIW
- **សកម្មភាពទី១៧៖** រំលឹកលើកឡើងវិញនៅសកម្មភាព I4C, CSC និង JAAP នៃការប្រជុំថ្នាក់ ឃុំ និង ស្រុកជាមួយដៃគូរពាក់ព័ន្ធ ។







## ៣. បញ្ហាប្រឈម និងដំណោះស្រាយ៖

| ល.រ | បញ្ហាប្រឈម | ដំណោះស្រាយ |
|---|---|---|
| ១ | CAFs មានការងាររវល់ច្រើន | បុគ្គលិកគម្រោងមានភាពបត់បែនផែនការធ្វើសកម្មភាពនៅពេល CAFs ទំនេរពីការងារស្ទូល ។ |
| ២ | សកម្មភាពច្រើន | បុគ្គលិកគម្រោងមានគ្នាតិចសកម្មភាពគម្រោងច្រើន ធ្វើមិនទាន់ផែនការដែលបានគ្រោងទុក ។ |
| ៣ | CAFs មានការផ្លាស់ប្តូរ | បុគ្គលិកគម្រោងបានសហការជាមួយប្រធាន CAFs ថ្នាក់ឃុំជ្រើសរើសថ្មីមកជំនួស ។ |

### ៣.២. គម្រោង គណនេយ្យភាពសង្គម ធ្វើឲ្យប្រសើរឡើងនូវសេវាសាធារណៈ (IMPLEMENTATION OF SOCIAL ACCOUNTABILITY FOR BETTER PUBLIC SERVICE DELIVERY PROJECT (I-SAF_PHASE II)៖

**ក. ចំនួនបុគ្គលិកសរុប** ៖ ៣ នាក់ (ស្រី ១នាក់)
**ខ. ទីតាំងគម្រោង** ៖ ខេត្ត កំពង់ឆ្នាំង (៤ស្រុក បរិបូណ៌ រលាប្អៀរ កំពង់លែង និងជលគិរី ១៤២សាលាបឋមសិក្សា ២១មណ្ឌលសុខភាព ៣៨រដ្ឋបាលឃុំ) ។
**គ. ម្ចាស់ជំនួយ** ៖ Trust Fund through WVI-C
**ឃ. សរុបថវិកាគម្រោង** ៖ ៣,៤០៧៦ ដុល្លារអាមេរិក
**ង. កាលបរិច្ឆេទគម្រោង** ៖ ៥ខែ (ថ្ងៃទី១ ខែកក្កដា ឆ្នាំ២០២០ ដល់ ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២០)

**១. គោលបំណងរបស់គម្រោង៖** ពង្រឹងតំរូវការនៃគណនេយ្យភាពសង្គមនៅក្នុងដំណើរការកែទម្រង់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិដើម្បីកែលម្អការផ្តល់សេវាសាធារណៈនៅកម្ពុជា ។

### ២. អ្នកទទួលផលសរុប៖

| អ្នកទទួលផលសរុប | ចំនួនអ្នកចូលរួម | |
|---|---|---|
| | សរុប | ស្ត្រី |
| អ្នកសម្របសម្រួលគណនេយ្យភាពសង្គម (CAFs) | ១៦៦ | ១២០ |
| ប្រជាពលរដ្ឋ (អ្នកទទួលសេវា) | ១១,០៥៤ | ៩,៦១០ |
| យុវជន (អាយុ ១៥-៣០) | ៨៤៧ | ៤០៩ |
| អាជ្ញាធរ (អ្នកផ្តល់សេវា) | ២,៣៥៦ | ១២១ |
| **សរុបរួម៖** | **១៤,៤២៣** | **១០,២៦០** |

### ៣. សកម្មភាពអនុវត្តគម្រោង៖

### ៣.១. លទ្ធផលសម្រេចបានពីការអនុវត្តគម្រោង៖

ក. <u>សមាសភាគទី១៖ តម្លាភាព ភាពងាយស្រួលក្នុងការទទួលបានព័ត៌មាននានា និងព័ត៌មានថវិកា៖</u>

- **សកម្មភាពទី១.១៖** មានកិច្ចសហការជាមួយ រដ្ឋបាលស្រុកជលគិរី (ស្រុកថ្មី) កិច្ចប្រជុំណែនាំទូទាំងស្រុក ស្តីការអនុវត្តផែនការសកម្មភាពគណនេយ្យភាពសង្គមរបស់របស់ស្រុក ដែលមានអ្នកចូលរួម ២៧នាក់ ស្រី ១២នាក់ ។

- **សកម្មភាពទី១.២៖** កិច្ចប្រជុំណែនាំទូទាំងឃុំ ស្តីពីការអនុវត្តផែនការសកម្មភាពគណនេយ្យភាពសង្គមរបស់ឃុំដែលមានកិច្ចសហការជាមួយ រដ្ឋបាលឃុំពាមឆ្កោក (ស្រុកថ្មី) ហើយមានអ្នកចូលរួមចំនួន ១៨នាក់ ស្រី ១៦នាក់

- **សកម្មភាពទី១.៦៖** កិច្ចប្រជុំផ្សព្វផ្សាយស្តីពីសិទ្ធិ ស្តង់ដារ និងតួនាទី (I4Cs) ដែលកម្មវិធីនេះអនុវត្តបានតែក្នុងស្រុកជលគិរី មានអ្នកចូលរួម៦៩៥នាក់ ស្រី៥៥៧នាក់ ។

**ខ. សមាសភាគទី២៖ ការត្រួតពិនិត្យតាមដានរបស់ប្រជាពលរដ្ឋ៖**

- **សកម្មភាពទី២.៣៖** កិច្ចប្រជុំវាយតម្លៃរបស់ពលរដ្ឋ លើរដ្ឋបាលឃុំ សាលាបឋមសិក្សា និងមណ្ឌលសុខភាព ដែលអនុវត្តលើជលគិរី មានអ្នកចូលរួមចំនួន៦៦៥នាក់ ស្រី៥៣១នាក់ ។
- **សកម្មភាពទី២.៦៖** កិច្ចប្រជុំឯកវិស័យ រវាងអ្នកផ្តល់សេវា និងអ្នកទទួលដែលមានអ្នកចូលរួមចំនួន ៨៤៧នាក់ ស្រី៤០៩នាក់ ។
- **សកម្មភាពទី២.៧៖** កិច្ចប្រជុំពហុវិស័យដើម្បីបង្កើតផែនការ ផ.ស.រ.គ ធ្វើលើស្រុកចំនួន រលាប្អៀរ កំពង់លែង និងស្រុកបរិបូណ៌ លើវិស័យបី រដ្ឋបាលឃុំ មណ្ឌលសុខភាព និងបឋមសិក្សា ។
- **សកម្មភាពទី២.៨៖** ការបង្កើតក្រុមគណៈកម្មាធិការផែនការ ផ.ស.រ.គ លើរដ្ឋបាលឃុំចំនួន៣៣ ដែលសមាសភាព លោកមេឃុំប្រធានគណៈកម្មាធិការ ផ.ស.រ.គ ។

**គ. សមាសភាគទី៣៖ ការអនុវត្តផែនការសកម្មភាពរួមស្តីពីការងារគណនេយ្យភាពសង្គម៖**

- **សកម្មភាពទី៣.៣៖** សមាហរណកម្មផែនការ ផ.ស.រ.គ ចូលក្នុងកម្មវិធីវិនិយោគឃុំ គ្រប់រដ្ឋបាលឃុំទាំង៣៣បាន សម្រេចយកផែនការ ផ.ស.រ.គ ដាក់បញ្ចូលក្នុងកម្មវិធីនិយោគឃុំ មានកូដសកម្មភាពនីមួយៗ ដែលយល់ព្រម វិភាគថវិការបស់ឃុំជួយវិស័យផ្សេងៗតាមលទ្ធភាពរបស់ខ្លួន ។

**ឃ. សមាសភាគទី៤៖ ការបណ្តុះបណ្តាល អភិវឌ្ឍន៍សមត្ថភាព និងការទំនាក់ទំនង៖**

- **សកម្មភាពទី៤.១៖** ប្រជុំជ្រើសរើសអ្នកស្ម័គ្រចិត្តសម្របសម្រួលគណនេយ្យភាពសហគមន៍ នៅស្រុកជលគិរី (ថ្មី) ចំនួន២០នាក់ ស្រី១៤នាក់ ។
- **សកម្មភាពទី៤.២៖** វគ្គបណ្តុះបណ្តាលដល់ CAFs ស្តីពីគណនេយ្យភាពសង្គមនិង កញ្ចប់ព័ត៌មានសម្រាប់ប្រជាពលរដ្ឋ នៅស្រុកជលគិរី ដែលមាន CAFs ចំនួន ២០នាក់ ស្រី១៤នាក់ ។
- **សកម្មភាពទី៤.៣៖** វគ្គបណ្តុះបណ្តាលដល់ CAFs ស្តីពីប័ណ្ណពិន្ទុសហគមន៍ ដែលអនុវត្តលើទាំង៤ស្រុកគោលដៅ មានអ្នកចូលរួមចំនួន ១៦៦នាក់ ស្រី១២០នាក់ ។
- **សកម្មភាពទី៤.៤៖** វគ្គបណ្តុះបណ្តាលដល់ CAFs ស្តីពីកិច្ចប្រជុំរួម និងផែនការផ.ស.រ.គ គម្រោងបានផ្តល់វគ្គបណ្តុះបណ្តាលអ្នកស្ម័គ្រចិត្តការងារគណនេយ្យភាពសង្គមចំនួន១៤៦នាក់ ស្រី១០៦នាក់ លើ៣ស្រុក កំពង់លែង រលាប្អៀរ និងស្រុកបរិបូណ៌ ។

## ៤. បញ្ហាប្រឈមរបស់គម្រោង៖

- គម្រោងសកម្មភាពមួយចំនួនត្រូវលើកពេលអនុវត្តដោយបញ្ហា កូវីត១៦
- ចំនួនអ្នកចូលរួមតាមប្រជុំនីមួយៗ មិនបានគ្រប់ចំនួន (តាមការកំណត់)
- រដ្ឋបាលឃុំមួយចំនួនមិនទាន់យល់យោបល់ច្បាប់ពីការងារគណនេយ្យភាពសង្គម(ស្រុកទើបអនុវត្ត) រដ្ឋបាលឃុំត្រូវការទាមទារលិខិតស្នាម និងការឯកភាពពីថ្នាក់លើ(ស្រុក)រាល់ការចុះអនុវត្តសកម្មភាពរបស់អ្នកសម្របសម្រួលគណនេយ្យភាពសង្គម (CAFs) ។
- រដ្ឋបាលខេត្ត/ស្រុក ពុំមានថវិកាគ្រប់គ្រាន់ក្នុងការចំណាយគាំទ្រសកម្មភាព ខាងផ្នែកអ្នកផ្តល់សេវា (Supply Sides) លើការងារពង្រឹងសមត្ថភាព និងតាមដានរបស់ក្រុមការងារថ្នាក់ស្រុក ៕

## ៥. សំណូមពររបស់គម្រោង៖

- សុំឱ្យក្រុមការងារថ្នាក់ឬស្រុកចេញបណ្ណសម្គាល់ខ្លួនអ្នកសម្របសម្រួលគណនេយ្យភាពសង្គម (CAFs)

- សុំឱ្យអាជ្ញាធរ ពិសេសក្នុងការងារគណនេយ្យភាពសង្គមខេត្ត/ស្រុក ចូលរួមសកម្មភាពមួយចំនួនរបស់ CAFs លើកម្មភាព ផ.ស.រ.គ ។
- ពន្លឿនកញ្ចប់ថវិកាថ្នាក់ជាតិ ដើម្បីបង្កើនសកម្មភាពចុះជួយក្រុមការងារថ្នាក់ស្រុក ។
- ក្រុមការងារថ្នាក់ខេត្ត/ស្រុក ធ្វើសេចក្ដីណែនាំដល់រដ្ឋបាលឃុំ ដើម្បីបង្កើតក្រុមការងារថ្នាក់ឃុំ ។

## ៣. សន្និដ្ឋានៈ

**អង្គការ សកម្មភាពព្រះពុទ្ធសាសនាដើម្បីអភិវឌ្ឍន៍សង្គម** គឺជាអង្គការក្រៅរដ្ឋាភិបាលក្នុងស្រុកមួយ ដែលកំពុងបានទទួលមូលនិធិដោយផ្ទាល់ពីអង្គការក្រៅស្រុកដូចជាអង្គការ EcoSolidar (មកពីប្រទេសស្វីស) Rotary Club (មកពីប្រទេសកាណាដា) La Maison Dés Enfant (មកពីប្រទេសបារាំង) និង GlobeMed (មកពីចក្រភពអង្គ្លេស) នឹងមូនិធិនៅក្នុងស្រុកដូចជាអង្គការ NORAD តាមរយៈ អង្គការ Save the Children, European Union តាមរយៈ អង្គការ World Vision International, European Union តាមរយៈ អង្គការ KAPE, Trust Fund តាមរយៈ អង្គការ World Vision International, Smile Restaurant នឹង Hanchey Bamboo Resort ដែលជាគម្រោងសហគ្រាសសង្គមរបស់អង្គការ BSDA ។ ដោយកំពុងតែបានអនុវត្តទៅលើកម្មវិធីធំៗចំនួនពីរ ដែលមានដូចជា៖ **(១). កម្មវិធីអប់រំ៖** ដែលមានគម្រោង៖ (ក). គម្រោងកុមារមេគង្គកម្ពុជា (ខ). គម្រោងអប់រំមូលដ្ឋាន និង (គ). គម្រោងអប់រំដើម្បីអណាគត់កុមារ **(២). កម្មវិធីសុខភាព៖** ដែលមានគម្រោង៖ (ក). គម្រោងធ្វើអោយប្រសើរឡើងនូវជីវភាពសហគមន៍ និង (ខ). អាជីវកម្មខ្នាតតូច **(៣). កម្មវិធីអភិបាលកិច្ចល្អ** ដែលមានគម្រោង៖ (ក). គម្រោងធ្វើអោយប្រសើឡើងរវាងអ្នកផ្ដល់ និងអ្នកទទួលសេវា វគ្គ១ និង (ខ). គម្រោងធ្វើអោយប្រសើឡើងរវាងអ្នកផ្ដល់ និងអ្នកទទួលសេវា វគ្គ២ ដែលកម្មវិធីទាំងអស់នេះកំពុងតែបានទៅដល់ កុមារក្រីក្រ កុមារងាយរងគ្រោះ កុមារបាត់បង់ឱកាស ពង្រឹងការអប់រំសិស្សកំរិតបឋម ពង្រឹងគុណភាពអប់រំតាមសាលា ការផ្ដល់ជំនាញវិជ្ជាជីវៈ និងប្រជាពលរដ្ឋនៅតាមសហគមន៍ ។ លទ្ធផលសម្រេចបានឆ្លើយតបទៅនឹងតម្រូវការរបស់ប្រជាពលរដ្ឋក្នុងសហគមន៍ និងចូលរួមចំណែកជាមួយរាជរដ្ឋាភិបាលក្នុងការកាត់បន្ថយភាពក្រីក្រ និងលើកកំពស់ជីវភាពរបស់ប្រជាពលរដ្ឋ ។

លើសពីនេះទៅទៀតអង្គការ សកម្មភាពព្រះពុទ្ធសាសនាដើម្បីអភិវឌ្ឍន៍សង្គម សំណើសុំឲ្យមានការសហការបន្ថែមទៀតពីសំណាក់អាជ្ញាធរ និងសហគមន៍ពាក់ពាក់ព័ន្ធនានា ដើម្បីឲ្យលទ្ធផលនៃការអនុវត្តគម្រោងទទួលបានប្រសិទ្ធភាពខ្ពស់ក្នុងគម្រោងនីមួយៗ ៕

ថ្ងៃអង្គារ ១២កើត ខែផល្គុន ឆ្នាំជូត ឯកស័ក ព.ស ២៥៦៤
កំពង់ចាម ថ្ងៃទី២៣ ខែកុម្ភៈ ឆ្នាំ២០២១

បានឃើញ និងឯកភាព
នាយកប្រតិបត្តិ

នាយកកម្មវិធី